# ព្រឹទ្ធសភា

# SENATE MAGAZINE

ទស្សនាវដ្ដីខែមិថុនា



លេខ ២៩៦ ឆ្នាំទី២៥ ព.ស.២៥៦៩ គ.ស.២០២៥

Issue 296 Volume 25 BC 2569 BE 2025

# មាតិកា







## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-៣៨ )


- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា ........ ១
- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា ដើម្បីអនុម័តសេចក្តីសម្រេចពាក់ព័ន្ធនឹងប្រធានបទចំនួន៣ សម្រាប់លើកកម្ពស់ឧត្តមប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ ........ ៣
- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ ........ ៨
- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំការបន្តសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥ ........ ៩
- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៥........ ១២
- ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងការធានាទូទាត់របស់រាជរដ្ឋាភិបាលឱ្យបណ្តាក្រុមហ៊ុនវិនិយោគ អភិវឌ្ឍថាមពលអគ្គិសនី និងសេចក្តីព្រាងច្បាប់ជលផល ........ ១៣
- សម្តេចតេជោ **ហ៊ុន សែន** ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្នើនាយករដ្ឋមន្ត្រីឱ្យកំណត់កូតាចំនួនស្ត្រីយ៉ាងតិច២រូប ជាអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ........ ១៧
- សម្តេចតេជោ ជំរុញឱ្យរុស្ស៊ីបង្កើតជើងហោះហើរត្រង់ពីទីក្រុងមូស្គូ មកប្រទេសកម្ពុជាឱ្យបានឆាប់ ........ ១៩
- សម្តេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យអនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសវៀតណាម ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ...... ២១
- ប្រទេសបង់ក្លាដែសស្នើសុំកម្ពុជាជំរុញវិស័យពាណិជ្ជកម្មនិងវិនិយោគរវាងប្រទេសទាំងពីរ ព្រមទាំងគាំទ្របង់ក្លាដែសធ្វើជាដៃគូរបស់អាស៊ាន .... ២៣
- សម្តេចតេជោ ស្នើរដ្ឋមន្ត្រីក្រសួងទេសចរណ៍ សិល្បៈ និងវប្បធម៌ម៉ាឡេស៊ី នាំសាររបស់សម្តេចជម្រាបជូននាយករដ្ឋមន្ត្រីម៉ាឡេស៊ី អំពីការពិតនៃបញ្ហាព្រំដែនកម្ពុជា-ថៃ ........ ២៥
- កម្ពុជាចង់ដោះស្រាយជម្លោះជាមួយថៃ ដោយសន្តិវិធី និងតាមតុលាការយុត្តិធម៌អន្តរជាតិ ........ ២៦
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួលម៉ាស៊ីនលាងឈាម និងឧបករណ៍វេជ្ជសាស្ត្រ........ ២៨
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជាអធិបតីក្នុងពិធីផ្តល់ជំនួយមនុស្សធម៌របស់មូលនិធិសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ជូនរដ្ឋបាលខេត្តកណ្តាល ........ ៣១
- សន្តិភាពត្រូវបានការពារដូចជាអាយុជីវិតរបស់យើង ហើយដែនដីត្រូវបានការពារដូចជាដួងព្រលឹងរបស់យើង........ ៣៣
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមកម្មវិធីផ្សេងៗ........ ៣៦


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ៣៩-៦៨ )


- គណៈកម្មការទី៩ព្រឹទ្ធសភាជួបពិភាក្សាជាមួយក្លឹបអ្នកកាសែតកម្ពុជា ជុំវិញនយោបាយការទូតសភាកម្ពុជា ........ ៣៩
- ឯកឧត្តម **ម៉ម ប៊ុននាង** នាំយកអំណោយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េប្រគល់ជូន រដ្ឋបាលខេត្តកំពង់ស្ពឺ ........ ៤១
- គណៈកម្មការទី១០ព្រឹទ្ធសភា ធ្វើបច្ចុប្បន្នភាពអនុស្សរណៈយោគយល់គ្នាជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដើម្បីនាំយកជំនួយមនុស្សធម៌ជូនដល់ប្រជាពលរដ្ឋនៅខេត្តតាកែវ និងខេត្តកំពត ........ ៤៣
- ក្រុមសមាជិកាព្រឹទ្ធសភា ជួបពិភាក្សានិងស្តាប់បទបង្ហាញរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីប្រមូលធាតុចូលសម្រាប់ សមាជិកព្រឹទ្ធសភាបំពេញមុខងារតំណាងឱ្យកាន់តែមានប្រសិទ្ធភាព ........ ៤៥
- ឯកឧត្តម **ម៉ម ប៊ុននាង** អញ្ជើញទទួលស្វាគមន៍ និងធ្វើបទបង្ហាញជូនប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន មកទស្សនកិច្ច ស្វែងយល់អំពីព្រឹទ្ធសភាកម្ពុជា........ ៤៧
- សាស្ត្រាចារ្យ និស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដាចំនួន១០០នាក់ ទស្សនកិច្ចសិក្សាស្វែងយល់អំពីព្រឹទ្ធសភា ........ ៤៩
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា........ ៥១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨........ ៥៨
- ការទទួលពាក្យបណ្តឹង........ ៦២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ........ ៦៨
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ ........ ៦៨


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៦៩-៧៣ )


- ឯកឧត្តម ឡាយ សំកុល ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២៥........ ៦៩
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ........ ៧១



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម ឡាយ សំកុល

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម ខេង សិទ្ធិគុណ

ឯកឧត្តម ជាម សុផលមករា

ឯកឧត្តម ជួន ណា

លោក ជួន សុខជី

លោក ទេព មករា

លោក កុក វ៉េ

លោក សុង សុខភារ័ត្ន

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោក ធុន គីមជី

លោកស្រី សុខ សុជាតា


**ក្របមុខ**

*សម្តេចតេជោ ហ៊ុន សែន អញ្ជើញដឹកនាំកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា នៅវិមានរដ្ឋសភា។*

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការ សមាជរដ្ឋសភានិងព្រឹទ្ធសភា



*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

នៅព្រឹកថ្ងៃចន្ទ ទី២៦ ខែឧសភា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានសមាជរដ្ឋសភានិងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

កិច្ចប្រជុំប្រព្រឹត្តទៅដោយមានវត្តមានចូលរួមពី សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា និងជាអនុប្រធានគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ និងឯកឧត្តម **ឆន់ ខឡុនា** អនុប្រធានទី២នៃព្រឹទ្ធសភា ឯកឧត្តម **ខង សូត** អនុប្រធានទី២រដ្ឋសភា ជាសមាជិកគណៈកម្មាធិការ សមាជរដ្ឋសភានិងព្រឹទ្ធសភា ព្រមទាំងឯកឧត្តម លោកជំទាវ ជាជំនួយការគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា។





*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា*

អង្គប្រជុំបានដំណើរការតាមរបៀបវារៈនិងបានសម្រេចលទ្ធផល ដូចខាងក្រោម៖

១-បានអនុម័តលើសំណើសុំបញ្ចូលក្នុងរបៀបវារៈប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា នូវប្រធានបទ៖

១.១-ប្រព័ន្ធគាំពារសង្គម។

១.២-សេដ្ឋកិច្ចក្រៅប្រព័ន្ធ។

១.៣-វិស័យកសិកម្ម។

២-បានអនុម័តនូវសមាសភាពលេខាធិការអង្គប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា ចំនួន៤រូប រួមមាន៖

១-ឯកឧត្តម យុត ចាន់ដារ៉ា

២-ឯកឧត្តម សេង ញ៉ក់

៣-ឯកឧត្តម ម៉ាន់ ឈឿន

៤-ឯកឧត្តម ឈើយ ចាន់ណា

៣-បានអនុម័តសេចក្ដីព្រាងរបៀបវារៈទី១ ទី២ ទី៣ និងកាលបរិច្ឆេទប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅថ្ងៃទី២ និងទី៣ ខែមិថុនា ឆ្នាំ២០២៥ នៅវិមានរដ្ឋសភា ដែលមានរបៀបវារៈចំនួនបី ដូចខាងក្រោម៖

១-ការពិភាក្សានិងអនុម័តប្រធានបទអំពីប្រព័ន្ធគាំពារសង្គម។

២-ការពិភាក្សានិងអនុម័តប្រធានបទអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

៣-ការពិភាក្សានិងអនុម័តប្រធានបទអំពីវិស័យកសិកម្ម៕



អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា*

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា ដើម្បីអនុម័តសេចក្តីសម្រេចពាក់ព័ន្ធនឹងប្រធានបទចំនួន៣ សម្រាប់លើកកម្ពស់ឧត្តមប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ



*សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា*

ប្រធានបទចំនួន៣រួមមាន ទី**១**-ប្រព័ន្ធគាំពារសង្គម ទី**២**-សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងទី**៣**-វិស័យកសិកម្ម ត្រូវបានអង្គប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា លើកយកមកពិភាក្សារយៈពេល២ថ្ងៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិងជាប្រធានសមាជរដ្ឋសភានិងព្រឹទ្ធសភា នៅវិមានរដ្ឋសភា នាថ្ងៃទី២ និងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៥ ចំណាយពេលវេលាប្រមាណ២៨ម៉ោង។

អង្គសមាជបានដំណើរការដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៦២រូបនិងសមាជិករដ្ឋសភាចំនួន១២៥រូប សរុបទាំងអស់ចំនួន១៨៧រូប ព្រមទាំងបានអនុម័តសេចក្តីសម្រេចចំនួនបី ទាក់ទងនឹងប្រធានបទទាំងបីខាងលើ ដែលត្រូវបានចាត់ទុកថាជាឯកសារគតិយុត្ត ដែលមានតម្លៃខ្ពស់បំផុតក្នុងការគាំទ្រលើកកម្ពស់ប្រសិទ្ធភាព ការអនុវត្តយុទ្ធសាស្ត្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍ជាតិ ឆ្នាំ២០៣០និងឆ្នាំ២០៥០។

សូមជម្រាបថា សមាជរដ្ឋសភានិងព្រឹទ្ធសភាលើកទី១នេះ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ នៃការបើកសម័យប្រជុំរួមគ្នារបស់សមាជិកព្រឹទ្ធសភានិងរដ្ឋសភា ក្នុងការពិភាក្សាដេញដោលលើការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលជាការបង្ហាញអំពីដំណើរការលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការទទួលខុសត្រូវ លើការអនុវត្តភារកិច្ចរបស់ស្ថាប័ននីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងស្ថាប័នពាក់ព័ន្ធឆ្លើយតបនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។



*សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ឡើងថ្លែងបទអន្តរាគមន៍*

មុនចូលរបៀបវារៈ អង្គសមាជបានឯកភាពគ្នាជាឯកច្ឆន្ទចេញសេចក្តីថ្លែងការណ៍គាំទ្រយន្តការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជាប្រមុខ ក្នុងការដោះស្រាយបញ្ហាព្រំដែន ជាមួយប្រទេសថៃ តាមរយៈដំណើរការការទូត ការចរចា ស្វ័យការពារខ្លួន និងការប្រើប្រាស់ច្បាប់អន្តរជាតិ។ អង្គសមាជគាំទ្រពេញទំហឹងចំពោះការនាំយកបញ្ហាប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបី ទៅដោះស្រាយនៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) «ដែលជាវិធីដើម្បីពន្លត់ភ្លើង ជាជាងអង្គុយបក់ផ្សែង»។

អង្គសមាជបានដំណើរការទៅតាមរបៀបវារៈដោយទទួលលទ្ធផល មានដូចខាងក្រោម៖

**១-ការពិភាក្សាលើប្រធានបទស្តីពី ប្រព័ន្ធគាំពារសង្គម**

ឯកឧត្តម **យស ផានីត្តា** តំណាងក្រុមជំនួយការគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា ទទួលបន្ទុកប្រធានបទអំពីប្រព័ន្ធគាំពារសង្គម បានរាយការណ៍ជូនអង្គប្រជុំសមាជស្តីពី ការពិនិត្យនិងសិក្សាលើប្រធានបទអំពីប្រព័ន្ធគាំពារសង្គម។



*ឯកឧត្តម យស ផានីត្តា ឡើងអានរបាយការណ៍*

នៅក្នុងប្រធានបទទី១នេះ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានជម្រាបជូនអង្គសមាជថា រាជរដ្ឋាភិបាលគ្រប់ដំណាក់កាលតែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះសុខុមាលភាពរបស់ប្រជាពលរដ្ឋ ការស្តារជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយផ្តោតលើសន្តិសុខស្បៀង ការផ្តល់សេវាសុខាភិបាលការអប់រំ សេវាសង្គម និងការសាងសំណាញ់សុវត្ថិភាពសង្គម។ រាជរដ្ឋាភិបាលនីតិកាលទី៧ ដែលជារាជរដ្ឋាភិបាលបន្តវេន របស់គណបក្សប្រជាជនកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ សម្រាប់ឆ្នាំ២០២៣-២០២៨ និងបានផ្តោតទៅលើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។ ដើម្បីកសាងប្រព័ន្ធគាំពារសង្គមឱ្យមានភាពរឹងមាំ ភាពធន់ និងប្រសិទ្ធភាពដូចសព្វថ្ងៃ រាជរដ្ឋាភិបាលបានវិនិយោគលើការកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់អភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដោយផ្តោតលើធាតុសំខាន់ៗចំនួន៣ រួមមាន៖ ទី**១**-ក្របខ័ណ្ឌគតិយុត្តនិងឯកសារគោលនយោបាយ ទី**២**-ប្រព័ន្ធគាំពារសង្គមឌីជីថល និងយន្តការតាមដានវាយតម្លៃ និងទី**៣**-ក្របខ័ណ្ឌស្ថាប័ន ក្នុងនោះរាជរដ្ឋាភិបាល បានរៀបចំនិងដាក់ចេញលិខិតបទដ្ឋានគតិយុត្ត ឯកសារក្របខ័ណ្ឌផែនទីបង្ហាញផ្លូវយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសំខាន់ៗ សម្រាប់ធ្វើស្ថាប័នូបនីយកម្ម ដាក់ឱ្យអនុវត្ត ក៏ដូចជាជំរុញការអនុវត្តកម្មវិធីជាតិជំនួយសង្គម របបសន្តិសុខសង្គម និងអន្តរាគមន៍គាំពារសង្គមជាបន្តបន្ទាប់។

**សម្តេចធិបតី**បានបញ្ជាក់ថា គិតត្រឹមខែមេសា ឆ្នាំ២០២៥ កម្មវិធីជាតិជំនួយសង្គម បានគ្របដណ្តប់លើពលរដ្ឋសរុបប្រមាណ១,២លានគ្រួសារ មានប្រមាណ៤,៨៤លាននាក់ ស្មើនឹង២៨% នៃចំនួនពលរដ្ឋសរុប។ ក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានវិភាជថវិកាប្រមាណ២៥៧លានដុល្លារអាម៉េរិកសម្រាប់អនុវត្តកម្មវិធីចំនួន៩។ គិតត្រឹមខែមេសា ឆ្នាំ២០២៥ របបសន្តិសុខសង្គមបានគ្របដណ្តប់លើពលរដ្ឋប្រមាណ៣.១លាននាក់ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន ហើយក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានវិភាជថវិកាប្រមាណ៤២៥លានដុល្លារអាម៉េរិកបន្ថែមលើថវិកាវិភាគទានដែលប្រមូលបានពីសមាជិក ប.ស.ស សម្រាប់អនុវត្តរបបសន្តិសុខសង្គម។ ចំណែកអន្តរាគមន៍ឆ្លើយតបទៅនឹងគ្រោះអាសន្នក្នុងខណៈដែលប្រទេសជាតិជួបគ្រោះអាសន្នដែលរួមមានការរីករាលដាលជំងឺកូវីដ-១៩ សម្ពាធអតិផរណានិងគ្រោះទឹកជំនន់ធ្ងន់ធ្ងរ រាជរដ្ឋាភិបាលបានគិតគូរនិងផ្តល់ការគាំពារដល់ពលរដ្ឋ ដើម្បីរក្សាលំនឹងជីវភាព កាត់បន្ថយការវិបាកអវិជ្ជមាន ដោយសារជីវភាពរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តាមរយៈការអន្តរាគមជំនួយសង្គម ពិសេសដល់គ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ ដែលបានចំណាយថវិកាជាតិសរុបប្រមាណ១៤២២លានដុល្លារអាម៉េរិក។

អង្គសមាជបានគាំទ្រទាំងស្រុងនូវការអនុវត្តយុទ្ធសាស្ត្រនិងគោលនយោបាយទាំងឡាយរបស់រាជរដ្ឋាភិបាល ដែលផ្តល់នូវសមិទ្ធផលនៃប្រព័ន្ធគាំពារសង្គម ដែលបានលើកកម្ពស់កម្រិតជីវភាព សុខុមាលភាព និងគុណភាពជីវិតរបស់ពលរដ្ឋ ព្រមទាំងបានជួយរក្សាលំនឹងជីវភាពក្នុងអំឡុងពេលជួបគ្រោះអាសន្ន និងលើកទឹកចិត្តរាជរដ្ឋាភិបាល ឱ្យបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដោយពង្រឹងអភិបាលកិច្ច ប្រកាន់ខ្ជាប់នូវអភិក្រម «ជវភាពនៃតួអង្គតែមួយ» និងបន្តអនុវត្តគោលនយោបាយគាំពារសង្គម ក្នុងកម្មវិធីគោលនយោបាយអាទិភាព និងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ ដែលបន្តផ្តល់ការទ្រទ្រង់ជីវភាពដល់ពលរដ្ឋគ្រប់រូប ជាពិសេសពលរដ្ឋក្រីក្រនិងងាយរងហានិភ័យ តាមរយៈការពង្រឹងយន្តការអនុវត្ត ការពង្រីកវិសាលភាពនៃកម្មវិធីជាតិជំនួយសង្គមនិងរបបសន្តិសុខសង្គមជាជំហានៗប្រកបដោយប្រសិទ្ធភាព

តម្លាភាព បរិយាបន្ន និងកាន់តែមានភាពងាយស្រួលក្នុងការទទួលបាន រួមទាំងបន្តពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកលនិងជំរុញការកែទម្រង់របបសោធននានា ដោយបង្កើតនូវប្រព័ន្ធសោធនជាតិរួមដែលមាននិរន្តរភាព។

សមាជរដ្ឋសភានិងព្រឹទ្ធសភា លើកទឹកចិត្តឱ្យព្រឹទ្ធសភានិងរដ្ឋសភាបន្តគាំទ្ររាជរដ្ឋាភិបាលក្នុងការអនុម័តច្បាប់ទាំងឡាយ ដែលជួយដោះស្រាយនូវបញ្ហាប្រឈម និងតម្រូវការរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

បន្ទាប់ពីសមាជិកសមាជរដ្ឋសភានិងព្រឹទ្ធសភាចំនួន២៤រូប ឡើងបញ្ចេញមតិយោបល់រួចមក អង្គសមាជបានអនុម័តលើសេចក្តីសម្រេចស្តីពី ប្រព័ន្ធគាំពារសង្គម ដោយចំនួន១៨១សំឡេង នៃចំនួនសមាជិកសមាជរដ្ឋសភានិងព្រឹទ្ធសភាទាំងមូល។

**២-ការពិភាក្សាលើប្រធានបទអំពី សេដ្ឋកិច្ចក្រៅប្រព័ន្ធ៖**

លោកជំទាវ **និន សាផុន** តំណាងក្រុមជំនួយការគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា ទទួលបន្ទុកប្រធានបទអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានឡើងរាយការណ៍ជូនអង្គប្រជុំសមាជស្តីពី ការពិនិត្យនិងសិក្សាលើប្រធានបទអំពី សេដ្ឋកិច្ចក្រៅប្រព័ន្ធ។



*លោកជំទាវ និន សាផុន ឡើងអានរបាយការណ៍*

សម្រាប់ប្រធានបទទី២នេះ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានជម្រាបអង្គសមាជជ្រាបថា គោលបំណងកែលម្អជីវភាពប្រជាពលរដ្ឋនឹងអាចរួមចំណែកជាអតិបរមា ក្នុងការឈានទៅសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន ភាពរឹងមាំ និងភាពធន់នឹងវិបត្តិ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ដែលជាកម្មវិធីទី៤ នៃកម្មវិធីគោលនយោបាយអាទិភាពចំនួន៦ ក្នុងគោលដៅលើកទឹកចិត្តអ្នកប្រកបរបរ និងធ្វើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរីកធំធាត់ មានលទ្ធភាពឈានចូលក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ។

យោងតាមការអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩ កម្ពុជាមានកម្លាំងពលកម្មប្រមាណ៧,៩លាននាក់ដោយនៅក្នុងនោះ២១,៥% ឬស្មើ១,៧លាននាក់ ធ្វើការនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ខណៈដែលកម្លាំងពលកម្ម ដ៏ច្រើនគឺ៦,២លាននាក់ ធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធភាគច្រើនខ្វះលទ្ធភាពទទួលបានសេវាសំខាន់ៗ ដែលធ្វើឱ្យពួកគាត់ងាយរងគ្រោះដោយសារវិបត្តិ។

អង្គសមាជបានអបអរសាទរនិងកោតសរសើររាជរដ្ឋាភិបាល ដែលបានខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់ជំរុញអភិវឌ្ឍគាំទ្រនិងជួយសម្របសម្រួលដល់ពលរដ្ឋ ដែលកំពុងប្រកបមុខរបរធ្វើការងារនិងមានអាជីវកម្មក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងបង្កើតឱកាសដល់ប្រជាពលរដ្ឋអាចអភិវឌ្ឍអាជីវកម្មនិងពង្រីកមុខរបរ ជាពិសេសធ្វើឱ្យកម្រិតជីវភាពនិងសុខុមាលភាពរបស់ពលរដ្ឋកាន់តែប្រសើរ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានរៀបចំនិងអនុវត្តការងារសំខាន់ៗដូចជា អនុក្រឹត្យស្តីពី ការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការបង្កើតថ្នាលឌីជីថលសម្រាប់ចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ វិធានការគាំទ្រនិងកញ្ចប់អត្ថប្រយោជន៍ផ្នែកពន្ធដារ ផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្នែកគាំពារសង្គម ផ្នែកហិរញ្ញវត្ថុធនាគារ ព្រមទាំងមានយន្តការត្រួតពិនិត្យតាមដាននិងវាយតម្លៃថែមទៀត។

ទន្ទឹមគ្នានេះ អង្គសមាជបានគាំទ្រនិងថ្លែងការកោតសរសើរចំពោះយុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ ដែលដាក់ចេញដោយរាជរដ្ឋាភិបាល ថាជាយុទ្ធសាស្ត្រដ៏ត្រឹមត្រូវ ស្របនឹងស្ថានភាពសេដ្ឋកិច្ចនិងសង្គមកម្ពុជាបច្ចុប្បន្ននិងទៅអនាគត ក្នុងរយៈពេលនៃអាណត្តិទី៧នេះ។ អង្គសមាជបានលើកឡើងថា យុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ពិតជាស្របទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១

របស់រាជរដ្ឋាភិបាល ដែលផ្តោតលើកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព។ អាទិភាពគន្លឹះទាំង៥ មានមនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាឌីជីថល ក៏បានគាំទ្រដល់យុទ្ធសាស្ត្រនេះ ក្នុងការឆ្លើយតបទៅនឹងនិន្នាការបដិវត្តឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៅកម្ពុជា សំដៅឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ យុទ្ធសាស្ត្រនេះ ក៏បានបង្ហាញពីកិច្ចការសំខាន់ៗដូចជា ការរៀបចំមូលដ្ឋានទិន្នន័យសម្រាប់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ បង្កើនការផ្សព្វផ្សាយនិងការយល់ដឹងជាសាធារណៈ និងភាពជាអ្នកដឹកនាំរបស់ក្រសួង ស្ថាប័ន។ ការសម្របសម្រួលអន្តរក្រសួង និងការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ និងសមាគមជាតិនិងអន្តរជាតិ គឺជាកិច្ចសហការដ៏សំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ។

អង្គសមាជបានអនុម័តសេចក្តីសម្រេចស្តីពី សេដ្ឋកិច្ចក្រៅប្រព័ន្ធ មានចំនួន១៨១សំឡេង នៃចំនួនសមាជិកសមាជរដ្ឋសភានិងព្រឹទ្ធសភាទាំងមូល បន្ទាប់ពីសមាជិកសមាជចំនួន២២រូបបានឡើងមានមតិយោបល់។

### ៣-ការពិភាក្សាលើប្រធានបទអំពី វិស័យកសិកម្ម

ឯកឧត្តមសន្តិបណ្ឌិត **ឡូយ សុផាត** តំណាងក្រុមជំនួយការគណៈកម្មាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា ទទួលបន្ទុកប្រធានបទអំពីវិស័យកសិកម្ម បានរាយការណ៍ជូនអង្គប្រជុំសមាជ នូវរបាយការណ៍ ស្តីពីការពិនិត្យ និងសិក្សាលើប្រធានបទអំពី វិស័យកសិកម្ម។



*ឯកឧត្តមសន្តិបណ្ឌិត ឡូយ សុផាត ឡើងអានរបាយការណ៍*

ដោយឡែកក្នុងប្រធានបទទី៣នេះ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានជម្រាបជូនអង្គសមាជជ្រាបថា រាជរដ្ឋាភិបាលមានកម្មវិធីគោលនយោបាយសំខាន់ចំនួន២ ដែលទាក់ទងនឹងវិស័យកសិកម្មគឺទី**១**-យន្តការសម្របសម្រួលនិងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ និងទី**២**-ការដាក់ពង្រាយមន្ត្រីកសិកម្មទៅគ្រប់ឃុំ សង្កាត់ ដែលមានសកម្មភាពនៅទូទាំងប្រទេសការរៀបចំសហគមន៍កសិកម្មនៅតាមទីជនបទ ដើម្បីបង្កើនល្បឿនអភិវឌ្ឍវិស័យកសិកម្មឱ្យក្លាយជាកម្លាំងចលករដ៏រឹងមាំនៅក្នុងការធានាសន្តិសុខស្បៀង ចូលរួមទ្រទ្រង់កំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។

គោលនយោបាយវិស័យកសិកម្ម គឺបម្រើដល់ផលប្រយោជន៍របស់ប្រជាជនកម្ពុជាគ្រប់រូប ដែលរួមមាន ទាំងអ្នករកទទួលទាននិងប្រជាកសិករ អ្នកបង្កបង្កើនផល តាមរយៈការអនុវត្តគោលនយោបាយសាមញ្ញ៤ចំណុច គឺមានហូប មានប្រើ មានបាន និងមានរហូត។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ និងកម្មវិធីគោលនយោបាយអាទិភាព ២ ក្នុងចំណោមកម្មវិធីគោលនយោបាយអាទិភាពទាំង៦ របស់រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តន៍ជាផ្លូវការ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។ រាជរដ្ឋាភិបាលនៅតែបន្តយកចិត្តទុកដាក់និងផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម ដែលនៅតែជាវិស័យអាទិភាព និងបន្តដើរតួនាទីសំខាន់ក្នុងការលើកស្ទួយជីវភាពប្រជាពលរដ្ឋ និងសេដ្ឋកិច្ចជាតិ បើទោះបីសេដ្ឋកិច្ចកម្ពុជាកំពុងរីកចម្រើនលើគ្រប់វិស័យក៏ដោយ។ ជារួមវិស័យកសិកម្ម នឹងនៅតែជាវិស័យយុទ្ធសាស្ត្រគន្លឹះសម្រាប់ធានាឱ្យបាននូវសន្តិសុខស្បៀងរបស់កម្ពុជា។

គិតត្រឹមឆ្នាំ២០២៤ វិស័យកសិកម្មបន្តចូលរួមចំណែកប្រមាណ១៦,៧% ក្នុងផលិតផលសរុបក្នុងស្រុក ហើយតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (Gross Value Added in Agriculture) បន្តកើនឡើងជារៀងរាល់ឆ្នាំពី ១៩ ៨០៥ពាន់លានរៀល (ប្រមាណ៤,៩៥ពាន់លានដុល្លារអាម៉េរិក) នៅឆ្នាំ២០១៥ ដល់ ២៤ ២៨២ពាន់លានរៀល (ប្រមាណ៦,០៧ពាន់លានដុល្លារ) នៅឆ្នាំ២០២០ និងដល់ ៣១ ២៩២ពាន់លានរៀល (ប្រមាណ៧,៨២ពាន់លានដុល្លារអាម៉េរិក) នៅឆ្នាំ២០២៤។ ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម រួមមានផ្នែកដំណាំ៦១,៣% ផ្នែកផលិតកម្មសត្វ ១៥,៤% ផ្នែកជលផល២០% និងផ្នែកព្រៃឈើ៣,៣%។





*ទិដ្ឋភាពក្នុងកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា*

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ តាមរយៈការអនុវត្តយ៉ាងសកម្មនូវគោលនយោបាយទូទៅ និងផែនការយុទ្ធសាស្ត្រក្នុងវិស័យកសិកម្ម ជាពិសេសយុទ្ធសាស្ត្រដែលត្រូវបានដាក់ចេញនិងអនុវត្តចាប់តាំងពីឆ្នាំ១៩៨៧ មក ស្ដីពីការផ្ទេរការអនុវត្តផ្ទាល់បែបបើកទូលាយមកកាន់ការអភិវឌ្ឍបែបស៊ីជម្រៅ ព្រមទាំងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ ដែលគួរបន្តអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ថែមទៀត ដើម្បីជាឧត្តមប្រយោជន៍ជាតិនិងប្រជាជន។ រាជរដ្ឋាភិបាលនីតិកាលមុនៗ និងនីតិកាលទី៧ នៃរដ្ឋសភា បាន ដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវស្របនឹងស្ថានភាពសេដ្ឋកិច្ចនិងសង្គមគ្រប់កាលៈទេសៈ។ ដោយឡែក សម្រាប់ កាលៈទេសៈបច្ចុប្បន្ន ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ប្រជាកសិករឱ្យកាន់តែមានប្រសិទ្ធភាព រាជរដ្ឋាភិបាលក៏បាន ដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ ចំនួន៣ចំណុច មាន៖**១**-ការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ **២**-រក្សាលំនឹងថ្លៃកសិផលតាមរយៈកម្មវិធីហិរញ្ញប្បទាន ទី**៣**-ការដាក់ពង្រាយមន្ត្រីកសិកម្មនៅតាមឃុំ សង្កាត់ និងការអភិវឌ្ឍសហគមន៍កសិកម្មទំនើប។

អង្គសមាជ បានគាំទ្រទាំងស្រុងនូវផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងវិធានការទាំងឡាយ ដែលបាន អនុវត្តកន្លងមកថា ស្របនឹងគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយ អាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យកសិកម្ម ដែលបានដាក់ចេញ។ ជាមួយគ្នានេះ អង្គសមាជបានលើកទឹកចិត្តដល់ រាជរដ្ឋាភិបាលឱ្យបន្តអនុវត្តគោលនយោបាយទូទៅ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ កម្មវិធីគោលនយោបាយ អាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យកសិកម្ម និងយុទ្ធសាស្ត្រ ដែលបានដាក់ចេញចាប់តាំងពីឆ្នាំ១៩៨៧ ស្ដីពីការផ្ទេរ ការអនុវត្តផ្ទាល់បែបបើកទូលាយមកកាន់ការអភិវឌ្ឍបែបស៊ីជម្រៅ តាមរយៈការដោះស្រាយទឹក ការបង្កើនការដាំដុះ និង ការធ្វើប្រពលវប្បកម្មលើផ្ទៃដីដែលមាន ដើម្បីឱ្យវិស័យកសិកម្មមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងវិបត្តិ ខាងក្រៅ បន្តធានាសន្តិសុខស្បៀងប្រកបដោយនិរន្តរភាព ជួយលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនិងចូលរួមចំណែកយ៉ាង សំខាន់ដល់សេដ្ឋកិច្ចជាតិ។

អង្គសមាជបានលើកទឹកចិត្តឱ្យព្រឹទ្ធសភានិងរដ្ឋសភា បន្តគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការអនុម័តច្បាប់ទាំងឡាយ ដែលជួយដោះស្រាយនូវបញ្ហាប្រឈមនិងតម្រូវការរបស់រាជរដ្ឋាភិបាល និងសូមថ្លែងអំណរគុណចំពោះស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដែលបានគាំទ្រកម្មវិធី នយោបាយរបស់រាជរដ្ឋាភិបាល និងសូមអំពាវនាវបន្តចូលរួមថែរក្សាសន្តិភាពនិងការអភិវឌ្ឍឱ្យបានគង់វង្សនិងមាន ចីរភាពជានិរន្តរ៍។

ក្រោយពីសមាជិកសមាជចំនួន២៣រូប បានឡើងមានមតិយោបល់រួចមក អង្គសមាជបានអនុម័តសេចក្ដីសម្រេច ស្ដីពីវិស័យកសិកម្ម មានចំនួន ១៧៧សំឡេង នៃចំនួនសមាជិកសមាជរដ្ឋសភានិងព្រឹទ្ធសភាទាំងមូល៕

អត្ថបទ៖ នាយកដ្ឋានព័ត៌មាន, រូបភាព៖ រដ្ឋសភា

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភានីតិកាលទី៥ នៅថ្ងៃព្រហស្បតិ៍ ទី២៩ ខែឧសភា ឆ្នាំ២០២៥ បានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ជនបទ បរិស្ថានធនធានទឹកនិងឧតុនិយមនៃព្រឹទ្ធសភាសុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥។

២-កំណត់កាលបរិច្ឆេទ និងរបៀបវារៈសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥។

៣-ផ្សេងៗ។

ក្រោយពីបានពិនិត្យ និងពិភាក្សារួចមក អង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃព្រហស្បតិ៍ ទី២៩ ខែឧសភា ឆ្នាំ២០២៥ នាវេលាម៉ោង៩:១៥នាទីព្រឹក ដើម្បីបន្តសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥ ដោយមានរបៀបវារៈដូចខាងក្រោម៖

១-ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។

២-ពិនិត្យនិងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា៕




*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំការបន្តសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥




*ឯកឧត្តម អ៊ុច បូរិទ្ធ* *សម្តេចតេជោ ហ៊ុន សែន* *ឯកឧត្តមបណ្ឌិត ជន់ វឌ្ឍនា*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែឧសភា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំការបន្តសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៧រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ ដូចខាងក្រោម៖

**របៀបវារៈទី១៖ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។**

យោងតាមស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ សម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥ ព្រឹទ្ធសភាបានប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មីចំនួន២រូប ដូចខាងក្រោម៖

១-លោកជំទាវ **ចឹក ហេង** ជាសមាជិកាព្រឹទ្ធសភា នៅមណ្ឌលភូមិភាគទី៨ (ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី) ជំនួស ឯកឧត្តម **មួង ម៉យ** ដែលបានទទួលមរណភាព។



*ឯកឧត្តម ឡាយ សំកុល ឡើងអានសេចក្តីសម្រេចទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី*



*ឯកឧត្តម អ៊ុន វណ្ណា* *លោកជំទាវ ចឹក ហេង*



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី ឡើងអានរបាយការណ៍*



*ឯកឧត្តម ប៊ិន ត្រឈៃ ឡើងការពារសេចក្តីព្រាងច្បាប់*

២-ឯកឧត្តម **អ៊ុន វណ្ណា** ជាសមាជិកព្រឹទ្ធសភានៅមណ្ឌលភូមិភាគទី៥ (ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប) ជំនួស ឯកឧត្តម **ទេព យុទ្ធី** ដែលបានទទួលមរណភាព។

សមាជិកព្រឹទ្ធសភាថ្មីទាំងពីររូបនេះ នឹងត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង។

**របៀបវារៈទី២៖ពិនិត្យនិងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។**

ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ជនបទ បរិស្ថាន ធនធានទឹក និងឧតុនិយម នៃព្រឹទ្ធសភា (គណៈកម្មការទី៣) បានឡើងធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំជ្រាប អំពី លទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់នេះថា សេចក្តីព្រាងច្បាប់ដែលតាក់តែងឡើងក្នុងគោលបំណង ដើម្បីវាយតម្លៃអំពីលទ្ធផលរួមនិងបញ្ហាប្រឈមចម្បងៗ ដែលបានកើតមានឡើងនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងដាក់ចេញនូវវិធានការ សកម្មភាព និងកម្មវិធីអាទិភាពទាំងឡាយជាលក្ខណៈ វិស័យនិងអន្តរវិស័យ ដែលជាមគ្គុទ្ទេសក៍សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការ យុទ្ធសាស្ត្ររបស់ខ្លួន ដោយតម្រឹមតម្រង់ជាមួយនឹងគោលដៅយុទ្ធសាស្ត្ររួមនៃការអភិវឌ្ឍជាតិ និងធានានូវបាវចនា ទាំង៥របស់យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គឺ កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ព្រមទាំង ការដាក់ចេញជាយន្តការមួយសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ សំដៅធានាការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ប្រកបដោយជោគជ័យ។

**ឯកឧត្តមបណ្ឌិត** បានបញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះ ក៏បានគិតគូរយ៉ាងច្បាស់លាស់គ្រប់ជ្រុងជ្រោយលើគ្រប់ ទិដ្ឋភាព និងមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នទាំងអស់ និងបានដាក់ចេញវិធានការ ផែនការសកម្មភាព កម្មវិធី អាទិភាពតាមវិស័យ និងសូចនាករសមិទ្ធកម្មច្បាស់លាស់ សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីម្ចាងជំរុញការ អនុវត្តឱ្យសម្រេចបានជោគជ័យនិងម្ខាងទៀតជំរុញការអនុវត្តវិធានការ ផែនការសកម្មភាព និងកម្មវិធីអាទិភាពតាម វិស័យ ដែលមានវឌ្ឍនភាពយឺត ឬមិនមានវឌ្ឍនភាព សំដៅធានាការអនុវត្តអាចប្រព្រឹត្តទៅរួមគ្នា ប្រទាក់ក្រឡាគ្នា និង បំពេញឱ្យគ្នាទៅវិញទៅមក ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។

បន្ទាប់ពីសមាជិកព្រឹទ្ធសភាចំនួន៣រូប ឡើងមានយោបល់ និងឯកឧត្តម **ចិន ផ្ទៃឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ បានឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភារួចមក អង្គប្រជុំព្រឹទ្ធសភាបានអនុម័តសេចក្តីព្រាងច្បាប់នេះ ដោយមានសំឡេងគាំទ្រ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

សូមជម្រាបថា សេចក្តីព្រាងច្បាប់នេះ គាក់តែងឡើងមាន៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន១០៣សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧។

គួររំលឹកផងដែរថា មុននឹងដំណើរការនៃអង្គប្រជុំតាមរបៀបវារៈ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានថ្លែងសារពិសេស តាមរយៈការផ្សាយបន្តផ្ទាល់តាមស្ថាប័នព័ត៌មាននានា ជូនដល់ជនរួមជាតិកម្ពុជាទាំងអស់អំពី សភាពការណ៍ជាក់ស្តែងនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ ពាក់ព័ន្ធនឹងហេតុការណ៍ប៉ះទង្គិចគ្នារវាងកងទ័ពកម្ពុជា-ថៃ នៅព្រំដែនតំបន់មុំបី ស្ថិតក្នុងខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។

**សម្តេចតេជោ**បានអំពាវនាវឱ្យជនរួមជាតិទាំងអស់ ជឿជាក់លើសមត្ថភាពរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហា និងគ្រប់គ្រងសភាពការណ៍ ជាពិសេសលើការចរចាជាជាងការប្រើប្រាស់កម្លាំងប្រដាប់អាវុធ។ **សម្តេចតេជោ** បានបញ្ជាក់បន្ថែមថា អ្វីដែលអាក្រក់បំផុត គឺព័ត៌មានក្លែងក្លាយ ដែលរុញឱ្យផ្ទុះសង្គ្រាម និងធ្វើឱ្យប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការនៅក្នុងគ្រប់វិស័យ និងខូចខាតផលប្រយោជន៍នៃទំនាក់ទំនងនៃប្រទេសទាំងពីរ។

បំណងប្រាថ្នារបស់**សម្តេចតេជោ**គឺចង់បានតំបន់ព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ ជាព្រំដែនសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។ ចុងបញ្ចប់ **សម្តេចតេជោ**ក៏បានផ្តាំផ្ញើការសាកសួរសុខទុក្ខនិងអរគុណដល់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងបានអំពាវនាវដល់ក្រសួង ស្ថាប័នទាំងអស់និងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈចូលរួមឧបត្ថម្ភគាំទ្រដល់កងទ័ពដែលនៅជួរមុខ ដើម្បីបង្ហាញពីភាពរួបរួមគ្នាជាធ្លុងមួយដ៏រឹងមាំនៃខឿនការពារជាតិរបស់កម្ពុជា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*ទិដ្ឋភាពក្នុងសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥*

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៥

របៀបវារៈចំនួន៥ ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាលើកយកមកប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នាព្រឹកថ្ងៃចន្ទ ទី១៦ ខែមិថុនា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា។ របៀបវារៈទាំង៥នោះ រួមមាន៖

១-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនី ចំនួន២៤ច្បាប់ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥។

២-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ជនបទ បរិស្ថាន ធនធានទឹក និងឧតុនិយម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ជលផល ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥។

៣-ពិនិត្យនិងសម្រេចលើការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥។

៤-កំណត់កាលបរិច្ឆេទនិងរបៀបវារៈបន្តសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥។

៥-ផ្សេងៗ។

ក្រោយពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានពិនិត្យនិងពិភាក្សារួចមក អង្គប្រជុំបានកំណត់យកថ្ងៃចន្ទ ទី១៦ ខែមិថុនា ឆ្នាំ២០២៥ នាវេលាម៉ោង៩:៣០នាទីព្រឹក នៅវិមានព្រឹទ្ធសភា ដើម្បីបន្តសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនី ចំនួន២៤ច្បាប់ និងសេចក្តីព្រាងច្បាប់ស្តីពីជលផល ព្រមទាំងការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ពាក់ព័ន្ធនឹងការធានាទូទាត់របស់រាជរដ្ឋាភិបាលឱ្យបណ្ដាក្រុមហ៊ុនវិនិយោគអគ្គិសនី និងសេចក្ដីព្រាងច្បាប់ជលផល




*ឯកឧត្តម អ៊ុច បូរិទ្ធ* *សម្ដេចតេជោ ហ៊ុន សែន* *ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា*

នាព្រឹកថ្ងៃចន្ទ ទី១៦ ខែមិថុនា ឆ្នាំ២០២៥ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ បានបន្តសម័យប្រជុំលើកទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា ដែលមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៦០រូប។



*សម្ដេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

មុននឹងចាប់ផ្ដើមដំណើរការអង្គប្រជុំនិងអនុលោមតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានថ្វាយព្រះពរសព្ទសាធុការ ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុ។ ក្នុងឱកាសនោះ **សម្ដេចតេជោ** ប្រធានព្រឹទ្ធសភា បានថ្លែងសារពិសេសតាមរយៈការផ្សាយផ្ទាល់តាមស្ថាប័នព័ត៌មាននានា ជូនដល់ជនរួមជាតិកម្ពុជាទាំងអស់ លើបញ្ហាបីសំខាន់ៗដូចខាងក្រោម៖

១-**សម្ដេចតេជោ** បានអំពាវនាវដល់ពលករខ្មែរទាំងអស់ដែលកំពុងធ្វើការនៅប្រទេសថៃ ទោះមានឬពុំមានលិខិតស្នាមក្ដី សូមត្រឡប់មកកម្ពុជាវិញ ក្នុងករណីមានការរើសអើង ឬប្រមាថពីពួកជ្រុលនិយមថៃនៅទីនោះ។ **សម្ដេចតេជោ** បានថ្លែងគាំទ្រសាររបស់**សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ដែលបានណែនាំដល់ក្រសួង ជំនាញ និងអាជ្ញាធរខេត្តពាក់ព័ន្ធទាំងអស់ ផ្ដល់ការសម្របសម្រួលនិងសហការនានា ព្រមទាំងផ្ដល់មធ្យោបាយដឹកជញ្ជូន ការស្នាក់នៅ ម្ហូបអាហារ ការថែទាំសុខភាពបឋម និងការជួយស្វែងរកការងារក្នុងស្រុក ជូនបងប្អូនពលករខ្មែរដែលត្រឡប់មកកម្ពុជាវិញ ដោយមិនអាចទុកពលរដ្ឋខ្មែរឱ្យក្រុមជ្រុលនិយមថៃប្រមាថមើលងាយនោះឡើយ។ **សម្ដេចតេជោ** ក៏បានថ្លែងអំណរគុណចំពោះសមាគមធនាគារនៅកម្ពុជា និងសមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលទទួលយកសំណូមពរ និងរួមគ្នាគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការជួយសម្រួលនិងបន្ថយបន្ទុកពលករខ្មែរ ដែលជាប់បំណុលធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពេលត្រឡប់មកកម្ពុជាវិញ។

២-ចំពោះការបិទច្រកចេញ-ចូលនានានៅតាមព្រំដែន សម្តេចតេជោ **ហ៊ុន សែន** បានបញ្ជាក់អំពីជំហរយ៉ាងច្បាស់លាស់ថា ភាគីកងទ័ពថៃគឺជាអ្នកបិទព្រំដែនមុនដោយឯកតោភាគី ហេតុនេះ ខាងកងទ័ពថៃត្រូវតែជាអ្នកបើកមុនវិញដែរ ដែលជាលក្ខខណ្ឌចាំបាច់បំផុតនាពេលនេះ ដើម្បីអាចសម្រួលឈានទៅរកប្រក្រតីភាពឡើងវិញដូចស្ថានភាពនៅមុនថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៥។ ប្រសិនបើភាគីថៃប្រកាសបើកព្រំដែនទាំងអស់ឡើងវិញ កម្ពុជានឹងបើកច្រកចេញ-ចូលជាប្រក្រតីឡើងវិញដែរ ហើយភាគីកម្ពុជាមិនមានភាពចាំបាច់ក្នុងការចូលរួមចរចាក្នុងការបើកព្រំដែនឡើងវិញនោះទេ។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងថា កម្ពុជាមានសេចក្តីថ្លៃថ្នូរ មានកិត្តិយស និងមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។

៣-ចំពោះការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការនាំយកបញ្ហាតំបន់មុំបី ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច និងប្រាសាទតាក្របី ទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) គឺដោយសារតែភាគីទាំងពីរពុំអាចស្រុះស្រួលគ្នាដោះស្រាយដោយយន្តការទ្វេភាគីបានទេ។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងថា ការចរចាតាមផ្លូវច្បាប់ និងការអនុវត្តច្បាប់អន្តរជាតិ គឺជាជម្រើសសន្តិភាពយូរអង្វែងសម្រាប់ប្រជាជាតិទាំងពីរ ជៀសវាងនូវការប្រើប្រាស់អាវុធ និងការបាត់បង់អាយុជីវិតមនុស្ស។ សម្តេចតេជោ **ហ៊ុន សែន** ក៏បានបង្ហាញក្តីរំពឹងថា បណ្តាប្រទេសនានាលើពិភពលោកនឹងគាំទ្រកម្ពុជា ក្នុងការជ្រើសរើសការដោះស្រាយបញ្ហាដោយសន្តិវិធី ដោយផ្អែកលើច្បាប់អន្តរជាតិ តាមរយៈយន្តការតុលាការយុត្តិធម៌អន្តរជាតិ ហើយក្រៅពីចំណុចទាំងបួនខាងលើនេះ កម្ពុជានឹងបន្តដោះស្រាយបញ្ហាជាមួយភាគីថៃ តាមរយៈយន្តការទ្វេភាគី។ គួរបញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ គឺគាប់ជួនចំថ្ងៃជាប្រវត្តិសាស្ត្រខួបទី៦៣ឆ្នាំ ដែលតុលាការយុត្តិធម៌អន្តរជាតិបានសម្រេចឱ្យកម្ពុជាឈ្នះលើរឿងក្តីប្រាសាទព្រះវិហារ (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២)។

មុននឹងបញ្ចប់ការថ្លែងសារពិសេស **សម្តេចតេជោប្រធានព្រឹទ្ធសភា**បានបញ្ជាក់យ៉ាងច្បាស់ឡើងវិញថា **សម្តេច**មិនដែលមានបំណងបញ្ឆេះឱ្យមានបញ្ហាជាតិនិយមនោះទេ និងបានអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជា សូមកុំធ្វើអំពើជ្រុលនិយម រើសអើងនិងប្រកាន់ពូជសាសន៍ចំពោះជនជាតិថៃ ដែលភាគច្រើនជាមនុស្សល្អ។

ជាកិច្ចបន្ត អង្គប្រជុំបានដំណើរការទៅតាមរបៀបវារៈ ដូចខាងក្រោម៖

**របៀបវារៈទី១៖ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនីចំនួន២៤ច្បាប់។**



*ឯកឧត្តម យស ផានីត្តា ឡើងអានរបាយការណ៍*

ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារនិងសវនកម្ម នៃព្រឹទ្ធសភា បានឡើងរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ថា សេចក្តីព្រាងច្បាប់ទាំង២៤នេះ រៀបចំឡើងក្នុងគោលបំណងដើម្បីផ្តល់ការធានាទូទាត់របស់រាជរដ្ឋាភិបាលដល់គម្រោងថាមពលអគ្គិសនីចំនួន២៤ ដែលជាឧបករណ៍ដ៏សំខាន់ដើម្បីធានាការឈានទៅសម្រេចបាននូវការផ្គត់ផ្គង់ថាមពលក្នុងរយៈពេលចំពោះមុខដល់ឆ្នាំ២០២៨ ស្របនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍

អគ្គិសនី ឆ្នាំ២០២២-២០៤០។

សេចក្តីព្រាងច្បាប់ទាំង២៤នេះ ក៏ជាលទ្ធផលនៃការខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តដ៏ម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល ចាប់តាំងពីនីតិកាលទី៦ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងអនុវត្តបន្តដ៏ខ្ជាប់ខ្ជួនដោយរាជរដ្ឋាភិបាលនីតិកាលទី៧ ដឹកនាំដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ក្នុងការកៀរគរស្វែងរកអ្នកវិនិយោគ និងការផ្តល់ហិរញ្ញប្បទានដល់គម្រោងនីមួយៗចាប់តាំងពីឆ្នាំ២០១៩ នៅពេលដែលមានការប្រែប្រួលនៃលទ្ធភាពផ្គត់ផ្គង់ថាមពលអគ្គិសនីនិងការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចជាតិ។

សេចក្តីព្រាងច្បាប់នីមួយៗ តាក់តែងឡើងមាន២មាត្រាត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន១០៣សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន៤រូប បានឡើងមានយោបល់និងឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភារួចមក អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់នីមួយៗ ដោយឥតកែប្រែចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ជលផល។**

ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ជនបទ បរិស្ថាន ធនធានទឹក និងឧតុនិយម នៃព្រឹទ្ធសភា បានឡើងរាយការណ៍ជូនអង្គប្រជុំអំពី លទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ថា សេចក្តីព្រាងច្បាប់ស្តីពីជលផល តាក់តែងឡើងក្នុងគោលបំណង គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍវិស័យជលផលឱ្យមានប្រសិទ្ធភាព សំដៅបន្តធានាសន្តិសុខស្បៀងប្រកបដោយនិរន្តរភាពសេដ្ឋកិច្ចនិងបរិស្ថាន ព្រមទាំងការពារសិទ្ធិនិងផលប្រយោជន៍ប្រជានេសាទ សហគមន៍នេសាទ វារីវប្បករ និងអាជីវករ ស្របតាមបរិបទនៃការរីកចម្រើនសេដ្ឋកិច្ចសង្គមនិងបច្ចេកវិទ្យា ចូលរួមក្នុងការគ្រប់គ្រងនិងអភិរក្សធនធានជលផលប្រកបដោយនិរន្តរភាពក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ ជាពិសេសប្រឆាំងនឹងសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

សេចក្តីព្រាងច្បាប់នេះ តាក់តែងឡើងមាន១៥ជំពូក ១០៤មាត្រា និងមានឧបសម្ព័ន្ធចំនួន២ ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូង



*ឯកឧត្តម កែវ រតនៈ ឡើងការពារសេចក្តីព្រាងច្បាប់*



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី ឡើងអានរបាយការណ៍*



*ឯកឧត្តម ខិត ទីណា ឡើងការពារសេចក្តីព្រាងច្បាប់*

ចំនួន១០៣សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧។




*សមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តច្បាប់*

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល បន្ទាប់ពីសមាជិកព្រឹទ្ធសភាចំនួន៦រូប ឡើងមានយោបល់និង ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

**របៀបវារៈទី៣៖បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា។**

សម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥ បានបោះឆ្នោតជាច់ដោយឡែកពីគ្នា ជ្រើសរើសលោកជំទាវ **ចឹក ហេង** ជាសមាជិកាគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា និងឯកឧត្តម **អ៊ុន ចន្ធ្លា** ជាសមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជនយុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីនៃព្រឹទ្ធសភា ដោយទទួលបានសំឡេងគាំទ្រចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភាអញ្ជើញបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី៤ និងទី៨ព្រឹទ្ធសភា*

# សម្តេចតេជោ ហ៊ុន សែន ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្នើនាយករដ្ឋមន្ត្រីឱ្យកំណត់កូតាចំនួនស្ត្រីយ៉ាងតិច២រូប ជាអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ



*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្នើទៅ**នាយករដ្ឋមន្ត្រី** ឱ្យកំណត់កូតាចំនួនស្ត្រីយ៉ាងតិចបំផុត២រូប ជាអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ខណៈកាលពីមុន កូតាចំនួនស្ត្រីជាអភិបាលរងមានត្រឹមតែចំនួន១រូបប៉ុណ្ណោះ។

**សម្តេចតេជោ**បានផ្តល់អនុសាសន៍យ៉ាងដូច្នេះ ក្នុងឱកាសដែលសម្តេចអនុញ្ញាតឱ្យប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីដឹកនាំដោយលោកជំទាវបណ្ឌិត **អ៊ឹង កន្ថាផាវី** ចូលជួបសម្តែងការគួរសមនិងទទួលអនុសាសន៍ នាព្រឹកថ្ងៃពុធ ទី៤ ខែមិថុនា ឆ្នាំ២០២៥ នៅវិមាន៧មករា។

**សម្តេចតេជោ**ក៏បានជំរុញឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ប្រជុំពិភាក្សាដើម្បីស្នើសុំយោបល់បន្ថែមពី**នាយករដ្ឋមន្ត្រី** ជាពិសេសរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ចំពោះការប្រឡងជ្រើសរើសមន្ត្រីរាជការជាស្ត្រី។ **សម្តេចតេជោ** បានផ្តល់អនុសាសន៍ថា គួរតែមានការកំណត់កូតាផ្តល់អាទិភាពដល់ការជ្រើសរើសមន្ត្រីរាជការជាស្ត្រី ក្នុងចំណោម ១០០ភាគរយ គួរតែផ្តល់កូតាដល់ស្ត្រីយ៉ាងតិចបំផុត៥០ភាគរយ ដើម្បីឱ្យស្ត្រីបានចូលរួមចំណែកក្នុងការងារជាមួយរាជរដ្ឋាភិបាលឱ្យបានកាន់តែច្រើន។

**សម្តេចតេជោ**បានបញ្ជាក់ថា ដើម្បីឱ្យស្ត្រីពង្រឹងពង្រីកនូវអនុត្តរភាពរបស់ស្ត្រី គឺត្រូវធ្វើឱ្យស្ត្រីមានភាពខ្លាំងមានអំណាចនៅគ្រប់វិស័យ ដោយចាប់ផ្តើមពីវិស័យសេដ្ឋកិច្ច។ មានន័យថា ឱ្យស្ត្រីកាន់តែខ្លាំងឡើងនៅក្នុងវិស័យសេដ្ឋកិច្ច





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម និងទទួលអនុសាសន៍*

របស់ប្រទេសកម្ពុជា ក៏ដូចជាការក្តោបសេដ្ឋកិច្ចនៅក្នុងគ្រួសាររបស់គាត់ ដើម្បីឈានទៅដល់ការលើកកម្ពស់និងធ្វើឱ្យស្ត្រីកាន់តែមានឥទ្ធិពលបន្ថែមទៀត។ **សម្តេចតេជោ**មានជំនឿថា យ៉ាងយូរបំផុត២០-៣០ឆ្នាំទៀត ឥទ្ធិពលនិងអនុត្តរភាពរបស់ស្ត្រី ក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិនិងគ្រួសារ នៅក្នុងប្រទេសកម្ពុជានឹងកាន់តែខ្លាំងឡើង។

**សម្តេចតេជោ**បានបញ្ជាក់បន្ថែមថា កាលពីសម្តេចធ្វើជានាយករដ្ឋមន្ត្រី **សម្តេច**បានសាងសង់កន្លែងស្នាក់នៅសម្រាប់គ្រូនិងសិស្សនៅតាមបណ្តាខេត្ត ប៉ុន្តែនៅរាជធានីភ្នំពេញមិនទាន់មានការសាងសង់នៅឡើយទេ។ ដោយមើលឃើញពីការលំបាកសម្រាប់ការស្នាក់នៅរបស់និស្សិតជាស្ត្រី នៅពេលមករៀនសូត្រនៅរាជធានីភ្នំពេញ **សម្តេចតេជោ**បានផ្តល់ថវិកាចំនួន១០លានដុល្លារអាមេរិក ដើម្បីសាងសង់កន្លែងស្នាក់នៅរបស់និស្សិតជាស្ត្រី លើផ្ទៃដីទំហំប្រមាណ២ហិកតាដើម្បីបន្សល់ជាមរតកជូនដល់និស្សិតជាស្ត្រី។ ថវិកានេះ មិនបានប្រើប្រាស់ថវិកាជាតិនោះទេ គឺជាថវិការបស់**សម្តេច**និងក្រុមគ្រួសារ។ អន្តេវាសិកដ្ឋាននេះ មានចំនួន១២០បន្ទប់ ស្មើនឹង៥០០នាក់ ដោយក្នុង១បន្ទប់ស្នាក់នៅបាន៤នាក់ មានបន្ទប់ទឹកនិងចង្ក្រានបាយ ព្រមទាំងសាងសង់ប៉ុស្តិ៍សុខភាពនៅជាន់ផ្ទាល់ដីផងដែរ។ នៅពេលកសាងរួចរាល់ **សម្តេច**នឹងប្រគល់ជូនក្រសួងកិច្ចការនារី ជាអ្នកគ្រប់គ្រងនិងចាត់ចែងក្នុងការទទួលនិស្សិតជាស្ត្រី ដែលខ្វះកន្លែងស្នាក់នៅពេលមករៀននៅរាជធានីភ្នំពេញ។



*លោកជំទាវបណ្ឌិត អ៊ឹង កន្థាផាវី អញ្ជើញរាយការណ៍*

**សម្តេចតេជោ**សង្ឃឹមថា អន្តេវាសិកដ្ឋាននេះនឹងជួយកាត់បន្ថយការលំបាករបស់និស្សិតជាស្ត្រី និងជួយពន្លឿនដល់ការវិនិយោគកសាងសមត្ថភាពរបស់ស្ត្រីនិងការចូលរួមរបស់ស្ត្រីក្នុងការកសាងប្រទេសជាតិ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម និងទទួលអនុសាសន៍*

# សម្តេចតេជោ ជំរុញឱ្យរុស្ស៊ីបង្កើតជើងហោះហើរត្រង់ពីទីក្រុងមូស្គូ មកប្រទេសកម្ពុជាឱ្យបានឆាប់




*ឯកឧត្តម Igor Krasnov និងសម្តេចតេជោ*

ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តម Igor Krasnov អគ្គរដ្ឋអាជ្ញានៃសហព័ន្ធរុស្ស៊ីចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានស្នើនិងជំរុញឱ្យប្រទេសរុស្ស៊ីបង្កើតជើងហោះហើរត្រង់ពីទីក្រុងមូស្គូ មកប្រទេសកម្ពុជា ដើម្បីជំរុញបន្ថែមទៀតនូវទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីរ។ ជាមួយគ្នានោះ **សម្តេច**ក៏បានជំរុញវិស័យសេដ្ឋកិច្ច វិនិយោគ ពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យមានការកើនឡើងបន្ថែមទៀត។

**សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ ពិតជាបាននាំមកនូវទំនាក់ទំនងដ៏រឹងមាំរវាងប្រទេសទាំងពីរ ទាំងស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ តាមរយៈដំណើរទស្សនកិច្ចនេះ នឹងជួយត្រួសត្រាយផ្លូវក្នុងការពង្រីកទំនាក់ទំនងទ្វេភាគីក្នុងការអនុវត្តច្បាប់និងវិស័យយុត្តិធម៌បន្ថែមទៀត។

**សម្តេចតេជោ** បានសម្តែងនូវការអបអរសាទរចំពោះឯកឧត្តមនិងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ដែលបានរៀបចំព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ កន្លងទៅ ដើម្បីរំលឹកខួបលើកទី៨០ នៃជ័យជម្នះរបស់សហភាពសូវៀតលើក្រុមណាស៊ីក្នុងសង្គ្រាមលោកលើកទី២។

ក្នុងឱកាសនោះ ឯកឧត្តម Igor Krasnov បានជម្រាបជូន**សម្តេចតេជោ** ជ្រាបថា ឯកឧត្តមនឹងរាយការណ៍ទៅថ្នាក់ដឹកនាំរុស្ស៊ី ដើម្បីធ្វើយ៉ាងណាជំរុញឱ្យមានការហោះហើរត្រង់ពីទីក្រុងមូស្គូមកកាន់ប្រទេសកម្ពុជាឱ្យបានឆាប់ ដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើង។

**ឯកឧត្តមអគ្គរដ្ឋអាជ្ញា** បាននាំនូវការសួរសុខទុក្ខពីសំណាក់ ឯកឧត្តម **វ្ល៉ាឌីមៀរ ពូទីន** ប្រធានាធិបតីរុស្ស៊ី ជូនចំពោះ**សម្តេចតេជោ** និងបានចាត់ទុក**សម្តេចតេជោ** គឺជាតួអង្គសំខាន់នៃការរួមចំណែកក្នុងទំនាក់ទំនងរវាងកម្ពុជានិងរុស្ស៊ី។

**ឯកឧត្តមអគ្គរដ្ឋអាជ្ញា** បានជម្រាបជូន**សម្តេចតេជោ** ជ្រាបអំពី ដំណើរទស្សនកិច្ចរបស់ឯកឧត្តមនៅកម្ពុជា ដើម្បីជួបជាមួយថ្នាក់ដឹកនាំកម្ពុជាមួយចំនួន ជាពិសេសជាមួយឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិភាក្សានិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗ ទាក់ទងនឹងវិស័យច្បាប់ និងការបណ្តុះបណ្តាល។ ក្នុងនោះ ឯកឧត្តមបានបញ្ជាក់អំពីគម្រោងរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីកម្ពុជា ក្នុងវិស័យយុត្តិធម៌ ពាក់ព័ន្ធនឹងវិស័យច្បាប់ក្នុងប្រទេសកម្ពុជានិងប្រទេសរុស្ស៊ី រួមទាំងកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំផងដែរ។

តាមរយៈ**ឯកឧត្តមអគ្គរដ្ឋអាជ្ញា** **សម្តេចតេជោ** បានមានប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខចំពោះឯកឧត្តម **វ្លាឌីមៀរ ពូទីន** ប្រធានាធិបតីរុស្ស៊ី និងឯកឧត្តម **ឌីមេទ្រី ម៉េដវេដេវ** ប្រធានគណបក្សរុស្ស៊ីរួបរួម។ បន្ថែមពីនេះ **សម្តេច** ក៏បានអញ្ជើញឯកឧត្តម **ដេមីទ្រី ម៉េដវេដេវ** ប្រធានគណបក្សរុស្ស៊ីរួបរួម មកបំពេញទស្សនកិច្ចនៅកម្ពុជា ក្នុងពេលវេលាសមស្របណាមួយ។

**សម្តេចតេជោ** បានរំលឹកអំពីគុណបំណាច់របស់រុស្ស៊ី ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់កម្ពុជា ជាពិសេសក្នុងអំឡុងពេលកម្ពុជាជួបការលំបាកកាលពីអតីតកាល។ បន្ថែមលើនេះ រុស្ស៊ីក៏បានចូលរួមចំណែកជួយអភិវឌ្ឍធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលនិស្សិតកម្ពុជាជាច្រើន បានទៅសិក្សានៅប្រទេសរុស្ស៊ី ដែលមកដល់ពេលនេះ និស្សិតទាំងអស់នោះបាននិងកំពុងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍឱ្យមានការរីកចម្រើន។

ជាការឆ្លើយតប **ឯកឧត្តមអគ្គរដ្ឋអាជ្ញា**បានសន្យាថា នឹងនាំយកនូវពាក្យពេចន៍របស់**សម្តេចតេជោ** ជូនចំពោះ**ឯកឧត្តមប្រធានាធិបតីរុស្ស៊ី**ផ្ទាល់ ជាពិសេសការសួរសុខទុក្ខ និងជំហររបស់**សម្តេចតេជោ** ក្នុងការដឹកនាំនិងជំរុញទំនាក់ទំនងរវាងប្រទេសទាំងពីរ ព្រមទាំងការអញ្ជើញឯកឧត្តម **ឌីមេទ្រី ម៉េដវេដេវ** មកបំពេញទស្សនកិច្ចនៅកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ, សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ*

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យអនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសវៀតណាម ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ



*នាយឧត្តមសេនីយ៍ ង្វៀន តិន គឿង និងសម្តេចតេជោ*

នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យនាយឧត្តមសេនីយ៍ **ង្វៀន តិន គឿង** (Nguyen Tan Cuong) អនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសវៀតណាមនិងជាអគ្គសេនាធិការកងទ័ពប្រជាជនវៀតណាម ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមាន៧មករា។

**សម្តេចតេជោ**បានសម្តែងនូវសេចក្តីពេញចិត្តចំពោះទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកម្ពុជា-វៀតណាម ដែលកាន់តែរឹងមាំនិងស្អិតល្មួត ផ្អែកលើស្មារតីមិត្តភាពប្រពៃណី សាមគ្គីភាព ភាពជាអ្នកជិតខាងល្អ និងកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ លើគ្រប់វិស័យ។ តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្តមមកកាន់កម្ពុជា នឹងរួមចំណែកពង្រឹងទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរបន្ថែមទៀត ពិសេសនៅក្នុងវិស័យកងទ័ព។

នៅក្នុងជំនួបនោះ ឯកឧត្តម **ង្វៀន តិន គឿង** បានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ**ដែលបានអនុញ្ញាតឱ្យឯកឧត្តមបានចូលជួប ហើយឯកឧត្តមក៏បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់**ឯកឧត្តម តូ ឡឹម អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម**និង**ឯកឧត្តមប្រធានរដ្ឋសភាវៀតណាម** ជូនចំពោះ**សម្តេចតេជោ**ផងដែរ។ ទន្ទឹមនឹងនេះ





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ*

ឯកឧត្តមបានថ្លែងអំណរគុណ**សម្តេចតេជោ** ដែលបានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមទិវាថ្ងៃរំដោះភាគខាងត្បូងនៃប្រទេសវៀតណាម កាលពីពេលកន្លងទៅ។

ឯកឧត្តម **ង្វៀន តិន ភឿង** បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនរបស់ប្រទេសកម្ពុជា ជាពិសេសការថែរក្សាបាននូវស្ថិរភាព សន្តិភាពនៅក្នុងប្រទេស និងភាពរីកចម្រើននៃសេដ្ឋកិច្ច។ ឯកឧត្តមក៏បានលើកឡើងអំពីគម្រោងនៃការសាងសង់ស្តូបមិត្តភាពកម្ពុជា-វៀតណាម នៅសារមន្ទីរនៃប្រទេសវៀតណាម។ គម្រោងនៃការសាងសង់ស្តូបនេះនឹងបង្ហាញអំពីទំនាក់ទំនងដ៏ស្អិតល្មួតរវាងកម្ពុជានិងវៀតណាម នៅគ្រប់កាលៈទេសៈ ជាពិសេសក្នុងវិស័យកងទ័ពដែលបានប្រឆាំងតវ៉ាពីអាណានិគម។

ឯកឧត្តម **ង្វៀន តិន ភឿង** បានពាំនាំនូវការអញ្ជើញរបស់**ឯកឧត្តម តូ ឡឹម អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម** ជូន **សម្តេចតេជោ** អញ្ជើញចូលរួមក្នុងទិវាអបអរសាទរថ្ងៃជ័យជម្នះ៨០ឆ្នាំ នៃថ្ងៃឯករាជ្យជាតិវៀតណាម នៅពេលខាងមុខ។

ជាការឆ្លើយតប **សម្តេចតេជោ** បានមានប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខត្រឡប់ទៅវិញ ជូនចំពោះ **ឯកឧត្តម តូ ឡឹម អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម** និង**ឯកឧត្តមប្រធានរដ្ឋសភាវៀតណាម**។ **សម្តេច**បានអរគុណដល់ភាគីវៀតណាមដែលនាពេលកន្លងទៅបានទទួលស្វាគមន៍**សម្តេច** និងប្រតិភូក្នុងឱកាសចូលរួមទិវាខួប៥០ឆ្នាំ នៃថ្ងៃរំដោះវៀតណាមភាគខាងត្បូង។

**សម្តេចតេជោ**បានបញ្ជាក់អំពីទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម ជាពិសេសព្រឹត្តិការណ៍ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ គឺជាខួប៤៧ឆ្នាំ នៃដំណើររបស់**សម្តេច**ឆ្ពោះទៅកាន់ប្រទេសវៀតណាម ដើម្បីស្វែងរកការរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍។ សម្រាប់ខួប៥០ឆ្នាំ ( ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ) **សម្តេច**នឹងអញ្ជើញចូលរួមដោយផ្ទាល់ ដើម្បីរំលឹកនូវប្រវត្តិសាស្ត្រក្នុងពេលដែល**សម្តេច**ធ្វើដំណើរចូលទៅកាន់ប្រទេសវៀតណាម ដោយយកអាយុជីវិតជាដើមទុន ដើម្បីមករំដោះប្រទេសជាតិ។

**សម្តេចតេជោ**បានលើកឡើងអំពីការពង្រឹងទំនាក់ទំនងនិងសហប្រតិបត្តិការលើវិស័យកងទ័ព ពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរ ឱ្យកាន់តែរឹងមាំបន្ថែមទៀត។ **សម្តេច**បានរំលេចថា ទាក់ទងនឹងការកសាងស្តូបអនុស្សាវរីយ៍កម្ពុជា-វៀតណាមនៅប្រទេសវៀតណាម គឺជាគំនិតផ្តួចផ្តើមរបស់សម្តេចស្នើឡើងតាំងពីមុនឆ្នាំ២០២០ ដើម្បីជាការឆ្លុះបញ្ចាំងអំពីការដឹងគុណគ្នាទៅវិញទៅមក។

**សម្តេចតេជោ** បានជំរុញឱ្យភាគីទាំងពីរ ( កម្ពុជា-វៀតណាម ) ជំរុញបន្ថែមទៀតក្នុងការបោះបង្គោលព្រំដែនដែលនៅសេសសល់១៦%ទៀត ឱ្យបានឆាប់រហ័ស៕

ប្រភព៖ Telegram Channel សម្តេចតេជោ, សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ*

# ប្រទេសបង់ក្លាដែសស្នើសុំកម្ពុជាជំរុញវិស័យពាណិជ្ជកម្មនិងវិនិយោគរវាងប្រទេសទាំងពីរ ព្រមទាំងគាំទ្របង់ក្លាដែសធ្វើជាដៃគូរបស់អាស៊ាន




*ឯកឧត្តម Faiyaz Murshid Kazi និងសម្តេចតេជោ*

ឯកឧត្តម Faiyaz Murshid Kazi ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែសប្រចាំព្រះរាជាណាចក្រកម្ពុជា បានស្នើសុំប្រទេសកម្ពុជាគាំទ្រដល់ប្រទេសបង់ក្លាដែសចំនួន២ចំណុច៖ **ទី១**-ការជំរុញពាណិជ្ជកម្ម វិនិយោគរវាងកម្ពុជានិងបង់ក្លាដែស ឱ្យកាន់តែមានការកើនឡើង និងសកម្មជាងមុន ពីព្រោះថា ចាប់តាំងពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ននេះ សក្តានុពលរបស់ប្រទេសកម្ពុជាមានការរីកចម្រើន និងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ **ទី២**-ស្នើសុំការគាំទ្រពីកម្ពុជាឱ្យបង់ក្លាដែសធ្វើជាដៃគូរបស់អាស៊ាន ក្នុងឱកាសចូលជួបសម្តែងការគួរសមជាមួយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៩ ខែមិថុនា ឆ្នាំ២០២៥។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានបញ្ជាក់ថា ប្រទេសបង់ក្លាដែសចង់ចូលរួមចំណែកធ្វើជាដៃគូក្នុងកិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយអាស៊ាន ជាពិសេសបញ្ហាមីយ៉ាន់ម៉ា។ ក្នុងនាមបង់ក្លាដែសជាប្រទេសជិតខាងជាប់នឹងប្រទេសមីយ៉ាន់ម៉ា បង់ក្លាដែសអាចចូលរួមសន្ទនាជួយដល់តំបន់អាស៊ានផងដែរ។

នៅក្នុងជំនួបនេះ **សម្តេចតេជោ**បានស្វាគមន៍និងគាំទ្រចំពោះជំហររបស់ប្រទេសបង់ក្លាដែសដែលចង់ធ្វើជាដៃគូរបស់អាស៊ានតាមអន្តរវិស័យ ដែលជាផ្នែកមួយជួយដល់ប្រទេសបង់ក្លាដែសក្នុងការពង្រីកទំនាក់ទំនងជាមួយអាស៊ានទាំងក្នុងក្របខណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្មនិងក្របខណ្ឌដទៃទៀត ជាពិសេសបញ្ហាមីយ៉ាន់ម៉ា។ **សម្តេចតេជោ** បានគាំទ្រក្នុងការជំរុញពាណិជ្ជកម្មឱ្យមានការវិនិយោគសេដ្ឋកិច្ចរវាងប្រទេសទាំងពីរឱ្យកាន់តែមានភាពល្អប្រសើរ។

**សម្តេចតេជោ**បានគូសបញ្ជាក់ថា ទំនាក់ទំនងស្នូលរវាងកម្ពុជានិងបង់ក្លាដែស គឺមិនអាចកាត់ផ្តាច់បានពីសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ព្រមទាំងការវិនិយោគបាននោះទេ។ **សម្តេច**បានផ្តល់ជាគំនិតថា ប្រទេសបង់ក្លាដែសគួរតែគិតគូរបន្ថែមក្នុងការចូលជាដៃគូនៃ RCEP ពីព្រោះថាបច្ចុប្បន្ន RCEP កំពុងតែបើកឱ្យសមាជិកចូលបន្ថែម ដូច្នេះជាឱកាសសម្រាប់

បង់ក្លាដែសអាចចូលជាសមាជិក RCEP ពីព្រោះប្រទេសបង់ក្លាដែសជាប្រទេសដែលមិនឆ្ងាយពីតំបន់អាស៊ីអាគ្នេយ៍នោះទេ។

នៅក្នុងឱកាសនោះផងដែរ **សម្ដេចតេជោ** ក៏បានជម្រាបអំពី ស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ និងស្នើឱ្យបង់ក្លាដែសគាំទ្រកម្ពុជាលើការដោះស្រាយបញ្ហាដោយសន្តិវិធីតាមរយៈយន្តការតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

នៅក្នុងជំនួបនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត**បានសម្ដែងនូវការពេញចិត្តចំពោះការផ្ដល់យោបល់របស់**សម្ដេចតេជោ** ដែលចង់ឱ្យបង់ក្លាដែសចូលជាសមាជិក RCEP ហើយឯកឧត្តមនឹងរាយការណ៍ទៅរដ្ឋាភិបាលបង់ក្លាដែស អំពីការចូលជាសមាជិក RCEP។ ជាមួយគ្នានោះ ឯកឧត្តមបានថ្លែងអំណរគុណចំពោះ**សម្ដេចតេជោ** និងរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់ដល់ជនជាតិបង់ក្លាដែសដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា។

**ឯកឧត្តមឯកអគ្គរដ្ឋទូត**បានសម្ដែងនូវការកោតសរសើរចំពោះភាពជាអ្នកដឹកនាំរបស់ **សម្ដេចតេជោ** ដោយចាត់ទុក**សម្ដេចតេជោ**ជាមេដឹកនាំដ៏អស្ចារ្យ ជាមេដឹកនាំដែលគួរឱ្យគោរពក្នុងចំណោមមេដឹកនាំល្បីៗនៅលើពិភពលោក និងជាមេដឹកនាំដ៏ឆ្នើមដែលពិភពលោកត្រូវការ។ ឯកឧត្តមសង្ឃឹមថា ទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកម្ពុជា និងបង់ក្លាដែស នឹងកាន់តែរីកចម្រើនបន្ថែមទៀត៕

ប្រភព៖ Telegram Channel សម្ដេចតេជោ, សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន







*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

# សម្តេចតេជោ ស្នើរដ្ឋមន្ត្រីក្រសួងទេសចរណ៍ សិល្បៈ និងវប្បធម៌ម៉ាឡេស៊ី នាំសាររបស់សម្តេចជម្រាបជូននាយករដ្ឋមន្ត្រីម៉ាឡេស៊ី អំពីការពិតនៃបញ្ហាព្រំដែនកម្ពុជា-ថៃ



*ឯកឧត្តម Dato SRI Tiong King Sing និងសម្តេចតេជោ*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តម Dato SRI Tiong King Sing រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សិល្បៈ និងវប្បធម៌នៃប្រទេសម៉ាឡេស៊ី ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៩ ខែមិថុនា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានស្នើឱ្យ**ឯកឧត្តមរដ្ឋមន្ត្រី** និង **ឯកឧត្តមឯកអគ្គរដ្ឋទូតម៉ាឡេស៊ី** ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួយនាំសាររបស់**សម្តេច**ជម្រាបជូន**ឯកឧត្តមនាយករដ្ឋមន្ត្រីម៉ាឡេស៊ី** ដែលជាប្រធានប្តូរវេនអាស៊ាននៅឆ្នាំនេះ អំពីការពិតនៃបញ្ហាព្រំដែនកម្ពុជា-ថៃ។ **សម្តេច**បានជម្រាបអំពីស្ថានភាពពិតប្រាកដនៃការកើតឡើងនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដោយការចាប់ផ្តើមចេញពីការបាញ់សម្លាប់ទាហានខ្មែរ កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥កន្លងទៅនេះ ដែលជាការប្រមាថមកលើកម្ពុជា និងការចូលឈ្លានពានក្នុងទឹកដីកម្ពុជា។ ជាមួយគ្នានោះ **សម្តេច**ក៏បានបញ្ជាក់អំពីបញ្ហានៃការបិទច្រកព្រំដែនដោយឯកតោភាគីរបស់ប្រទេសថៃ និងការប្រមាថព្រមទាំងការគំរាមបិទអគ្គិសនីនិងអ៊ីនធើណិតជាដើម។ **សម្តេច**បានបញ្ជាក់អំពីជំហររបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធីតាមរយៈយន្តការតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

**សម្តេចតេជោ** បានជំរុញឱ្យប្រទេសទាំងពីរកម្ពុជា-ម៉ាឡេស៊ី បន្តពង្រីកទំនាក់ទំនងទេសចរណ៍ជាមួយគ្នាឱ្យកាន់តែរីកចម្រើន តាមរយៈការបង្កលក្ខណៈងាយស្រួលដល់អ្នកទេសចរនៃប្រទេសទាំងពីរ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការជំរុញទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រជាជនប្រទេសទាំងពីរ។ **សម្តេច**ចង់ឱ្យមានការបង្កើនជើងហោះហើរត្រង់ពីម៉ាឡេស៊ី មកកាន់រាជធានីភ្នំពេញ ខេត្តសៀមរាបនិងខេត្តព្រះសីហនុ ដើម្បីពង្រីកវិស័យទេសចរណ៍បន្ថែមទៀត។

នៅក្នុងជំនួបនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃអនុញ្ញាតឱ្យឯកឧត្តមនិងសហការីបានជួបសម្តែងការគួរសមនៅពេលនេះ។ **ឯកឧត្តមរដ្ឋមន្ត្រី**បានសន្យាថា នឹងនាំយកសាររបស់**សម្តេចតេជោ**ទៅជម្រាបជូន**ឯកឧត្តមនាយករដ្ឋមន្ត្រីម៉ាឡេស៊ី**។ ឯកឧត្តមបានគាំទ្រចំពោះជំហររបស់កម្ពុជា ក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធី ជាពិសេសយន្តការដោះស្រាយនៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

**ឯកឧត្តមរដ្ឋមន្ត្រី**បានលើកឡើងអំពីសក្តានុពលនៃវិស័យទេសចរណ៍រវាងកម្ពុជានិងម៉ាឡេស៊ី ជាពិសេសចំនួននៃការកើនឡើងភ្ញៀវទេសចរកម្ពុជាទៅកាន់ប្រទេសម៉ាឡេស៊ី និងការកើនឡើងអ្នកទេសចរម៉ាឡេស៊ីមកកាន់ប្រទេសកម្ពុជាផងដែរ។Ⅱ

ប្រភព៖ Telegram Channel សម្តេចតេជោ, សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# កម្ពុជាចង់ដោះស្រាយជម្លោះជាមួយថៃ ដោយសន្តិវិធី និងតាមតុលាការយុត្តិធម៌អន្តរជាតិ





*ឯកឧត្តមនាយឧត្តមសេនីយ៍ Morishita Yasunori និងសម្តេចតេជោ*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ប្រាប់មេបញ្ជាការកងស្វ័យការពារជើងគោកជប៉ុនថា កម្ពុជាចង់ដោះស្រាយជម្លោះជាមួយថៃ ដោយសន្តិវិធីនិងតាមតុលាការយុត្តិធម៌អន្តរជាតិ ICJ ដើម្បីយុត្តិធម៌សម្រាប់ប្រទេសទាំងពីរ។ ការបញ្ជាក់របស់ **សម្តេចតេជោ** បានលើកឡើងក្នុងឱកាសដែលសម្តេចអនុញ្ញាតឱ្យឯកឧត្តមនាយឧត្តមសេនីយ៍ Morishita Yasunori មេបញ្ជាការកងស្វ័យការពារជើងគោកនៃប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃពុធ ទី២៥ ខែមិថុនា ឆ្នាំ២០២៥។

**សម្តេចតេជោ** បានពន្យល់អំពីស្ថានភាពបញ្ហាពិតប្រាកដនៃជម្លោះរវាងកម្ពុជា-ថៃ ដែលកំពុងកើតមានឡើងរហូតមកដល់ពេលបច្ចុប្បន្ននេះ គឺបានចាប់ផ្តើមដោយទាហានថៃចូលមកបាញ់សម្លាប់យុទ្ធជនកម្ពុជាក្នុងទឹកដីកម្ពុជា។ បន្ទាប់មក ទាហានថៃបានសម្រេចបិទច្រកព្រំដែនជាឯកតោភាគី និងមានសកម្មភាពជាច្រើនទៀតដែលទាហានថៃបានរំលោភមកកាន់កម្ពុជា ដែលជាហេតុធ្វើឱ្យកម្ពុជាត្រូវមានវិធានការក្នុងការទប់ស្កាត់ និងឆ្លើយតបទៅវិញ។ **សម្តេច**បានបញ្ជាក់ថា **សម្តេច**មិននឹកស្មានថា មានរឿងបែបនេះចំពោះបញ្ហាព្រំដែនរវាងប្រទេសទាំងពីរទាល់តែសោះ។ អ្វីដែល**សម្តេច**ចង់បាន គឺព្រំដែនមួយដែលមានកិច្ចសហប្រតិបត្តិការល្អ មិត្តភាព ព្រំដែនដែលមានការអភិវឌ្ឍរួមគ្នា។ **សម្តេច**មិនចង់ឃើញមានការផ្ទុះអាវុធឬសង្គ្រាមជាមួយគ្នាឡើយ គឺចង់ឃើញតែសន្តិភាពដែលបានកើតឡើង សម្រាប់ព្រំដែនប្រទេសកម្ពុជា។

ទន្ទឹមនោះ **សម្តេចតេជោ** បានស្នើឱ្យជប៉ុនជួយដោះស្រាយជម្លោះនៃប្រទេសទាំងពីរប្រកបដោយសន្តិវិធី និងគោរពតាមនិយាម ឬច្បាប់អន្តរជាតិ ដោយជំរុញឱ្យភាគីវិវាទទាំងពីរដោះស្រាយវិវាទតាមរយៈតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

ក្នុងជំនួបនេះ **ឯកឧត្តមមេបញ្ជាការកងស្វ័យការពារជើងគោកជប៉ុន** បានថ្លែងអំណរគុណ**សម្តេចតេជោ** ដែលបានបញ្ជាក់អំពី មូលហេតុ ស្ថានភាពពិត និងបញ្ហាព្រំដែនរបស់ប្រទេសកម្ពុជា ជាមួយប្រទេសថៃ។ ឯកឧត្តមបានបញ្ជាក់ថា អ្វីដែលជប៉ុនចង់បាន គឺការដោះស្រាយដោយសន្តិវិធីក្នុងបញ្ហាព្រំដែន។ តំណាងឱ្យកងទ័ពជប៉ុន ឯកឧត្តមបានចូលរួមរំលែកមរណទុក្ខរបស់យុទ្ធជនកម្ពុជា លោកព្រឹន្ទបាលឯក **សួន រ៉ោន** ដែលត្រូវបានទាហានថៃបាញ់សម្លាប់ កាលពី





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥កន្លងទៅថ្មីៗនេះ។

**សម្តេចតេជោ** បានអរគុណចំពោះ**ឯកឧត្តមមេបញ្ជាការកងស្វ័យការពារជើងគោកជប៉ុន** ដែលបានចូលរួមរំលែកមរណទុក្ខចំពោះយុទ្ធជនកម្ពុជា ដែលត្រូវបានទាហានថៃបាញ់សម្លាប់។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានសម្តែងនូវការពេញចិត្តចំពោះភាពជាដៃគូយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា និងប្រទេសជប៉ុន ដែលមានភាពរីកចម្រើនជាលំដាប់ ជាពិសេសក្នុងវិស័យការពារជាតិ។

**សម្តេចតេជោ** បានសម្តែងនូវក្តីរីករាយចំពោះនាវាជប៉ុន ដែលបានចូលចតនៅកំពង់ផែរាមដោយជោគជ័យ កាលពីខែមេសា កន្លងទៅ។ នេះគឺជាផ្លែផ្កាមួយនៃការពង្រឹកទំនាក់ទំនងទ្វេភាគីក្នុងក្របខ័ណ្ឌកងទ័ព នៃប្រទេសទាំងពីរ។ ជាមួយគ្នានោះ **សម្តេច**បានអបអរសាទរចំពោះ**ឯកឧត្តមមេបញ្ជាការកងស្វ័យការពារជើងគោកជប៉ុន** ដែលទទួលនូវគ្រឿងឥស្សរិយយសពីសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងអំឡុងពេលបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមគ្នានោះ **សម្តេចតេជោ** បានសង្កេតឃើញថា ផ្នែកពាណិជ្ជកម្មនិងផ្នែកវិនិយោគនៃប្រទេសទាំងពីរ ក៏មានការរីកចម្រើន និងកើនឡើងជាបន្តបន្ទាប់ ដែលជាផ្នែកមួយក្នុងការជំរុញនូវទំហំពាណិជ្ជកម្មនិងជាការរុញច្រាននូវទំនាក់ទំនងសេដ្ឋកិច្ច ព្រមទាំងនយោបាយឱ្យទៅជាមួយគ្នាផងដែរ៕

ប្រភព៖ Telegram Channel សម្តេចតេជោ, សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួល ម៉ាស៊ីនលាងឈាម និងឧបករណ៍វេជ្ជសាស្ត្រ



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួលម៉ាស៊ីនលាងឈាម និងឧបករណ៍វេជ្ជសាស្ត្រ*

នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំពិធីប្រគល់-ទទួល ម៉ាស៊ីនលាងឈាម និងឧបករណ៍វេជ្ជសាស្ត្ររបស់ក្រុមហ៊ុន តុងជឺ ម៉េឌីខល គ្រុប(Dongze Medical Group) នៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់ក្រសួងសុខាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

ពិធីដ៏មានអត្ថន័យនេះ ប្រព្រឹត្តទៅដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវជាសមាជិកសមាជិកាក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយសភាប្រឹក្សានយោបាយប្រជាជនចិន, គណៈប្រតិភូក្រសួងសុខាភិបាលដឹកនាំដោយ ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល, ប្រតិភូក្រុមហ៊ុន តុងជឺ ម៉េឌីខល គ្រុប ដឹកនាំដោយ ឯកឧត្តម **ចេកឃី សែ ចិន** ទីប្រឹក្សាសម្តេចតេជោ **ហ៊ុន សែន** និងជាប្រធានកិត្តិយសនៃមូលនិធិជំងឺក្រលៀនអាស៊ី-ប៉ាស៊ីហ្វិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន តុងជឺ ម៉េឌីខល គ្រុប ព្រមទាំងភ្ញៀវកិត្តិយស និងធុរជនជាតិ-អន្តរជាតិ។

ក្នុងឱកាសនោះ ឯកឧត្តម **ចេកឃី សែ ចិន** បានសម្តែងនូវការគោរពដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះសម្តេចតេជោ **ហ៊ុន សែន** ដែលបានយកចិត្តទុកដាក់និងគាំទ្រយ៉ាងជ្រាលជ្រៅ ចំពោះកិច្ចសហប្រតិបត្តិការចិន-កម្ពុជា រួមទាំងការព្យាបាលជំងឺក្រលៀន និងថ្លែងអំណរគុណចំពោះព្រឹទ្ធសភានិងក្រសួងសុខាភិបាល ដែលបានជួយជ្រោមជ្រែងក្នុងការអនុវត្តគម្រោងនេះដែលជាការរួមចំណែកដល់ការជួយអភិវឌ្ឍវិស័យសុខាភិបាលកម្ពុជា។ ការគាំទ្រទាំងអស់នេះជាការលើកទឹកចិត្តមិនអាចកាត់ថ្លៃបាន រួមចំណែកដល់ការពង្រឹងសុខភាពនិងសុខុមាលភាពប្រជាជនកម្ពុជា។ **ឯកឧត្តមទីប្រឹក្សា** បានសង្កត់ធ្ងន់ថា «ការបរិច្ចាគនិងកិច្ចសហប្រតិបត្តិការរបស់យើង នៅថ្ងៃនេះគឺជាជំហានដ៏រឹងមាំមួយឆ្ពោះទៅមុខក្នុងការកសាងសហគមន៍វាសនារួម ចិន-កម្ពុជា»។



ឯកឧត្តម អ៊ុច បូរិទ្ធ



ឯកឧត្តម ចេកឃី សៃ ចិន



ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត ឈាងរ៉ា





ទិដ្ឋភាពក្នុងពិធីប្រគល់-ទទួលម៉ាស៊ីនលាងឈាម និងឧបករណ៍វេជ្ជសាស្ត្រ

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល** បានថ្លែងគូសបញ្ជាក់ថា ការផ្តល់នូវឧបករណ៍លាងឈាមខាងលើ មិនត្រឹមតែបានជួយសង្គ្រោះអាយុជីវិតប៉ុណ្ណោះទេ ប៉ុន្តែគឺជាជំហានជាក់ស្តែងក្នុងការជួយជំរុញដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសុខាភិបាល ផ្តោតលើការផ្តល់សេវាសុខាភិបាល ដែលមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាពប្រកបដោយសមធម៌ និងបរិវត្តកម្មសុខាភិបាលឌីជីថល ព្រមទាំងចូលរួមចំណែកដល់ការផ្តល់សេវាថែទាំសុខភាពរបស់អ្នកជំងឺ ដើម្បីឈានទៅសម្រេចបានការគ្របដណ្តប់សុខភាពកាន់តែប្រសើរឡើង។

តាងនាមសម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានថ្លែងអំណរគុណចំពោះជំនួយរបស់ក្រុមហ៊ុនវេជ្ជសាស្ត្រ Dongze Medical ដែលជាការរួមចំណែកក្នុងការខិតខំពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខភាពសាធារណៈនិងការពារសុខុមាលភាពប្រជាពលរដ្ឋកម្ពុជា ដែលជាអាទិភាពទីមួយ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងនោះ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ការជួយឧបត្ថម្ភគាំទ្ររបស់រដ្ឋាភិបាលនិងប្រជាជនចិន ដល់ប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជា ទាំងនៅក្នុងគ្រាសុខសាន្តត្រាណ និងទាំងនៅក្នុងគ្រាលំបាក។ កាលពីអំឡុងពេលនៃការរីករាតត្បាតនៃជំងឺកូវីដ-១៩ ការគាំទ្ររបស់ប្រទេសចិនមិនកំណត់ថា ជាថ្នាំ






*ទិដ្ឋភាពក្នុងពិធីប្រគល់-ទទួល និងថតរូបអនុស្សាវរីយ៍*

បង្ការ ការផ្គត់ផ្គង់វេជ្ជសាស្ត្រ ឬជាជំនួយបច្ចេកទេសនោះទេ គឺមានភាពហ័សរហួននិងប្រកបដោយសមានចិត្តទូលំទូលាយ ទទួលបានការកោតសរសើរ និងដឹងគុណយ៉ាងជ្រាលជ្រៅពីរាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានលើកឡើងអំពីភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រជាជាតិទាំងពីរ ដែលបាននាំឱ្យមានការអភិវឌ្ឍជាក់ស្តែងក្នុងវិស័យជាច្រើន ចាប់ផ្តើមពីហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្មរហូតដល់វិស័យកសិកម្ម ការអប់រំ និងសុខភាពសាធារណៈ។ កិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរនេះ តែងតែឈរលើគោលការណ៍នៃការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង និងបំណងប្រាថ្នារួម ដើម្បីសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍនៅក្នុងតំបន់និងក្នុងពិភពលោក និងឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដ ព្រមទាំងកសាងអនាគតរួមមួយ ដែលគ្មានអ្នកណាម្នាក់ត្រូវបានទុកចោល។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានគូសបញ្ជាក់ថា ពិធីប្រគល់-ទទួលដ៏មហោឡារិកនាថ្ងៃនេះ គឺជាសក្ខីភាពដ៏រស់រវើកនៃការប្តេជ្ញាចិត្តរបស់ព្រឹទ្ធសភាកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងឈ្លាសវៃរបស់ **សម្តេចតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្រាប់ព្រឹទ្ធសភានីតិកាលទី៥ ក្នុងការកសាងស្ពានរវាងប្រជាជននិងប្រជាជន ព្រមទាំងជាការបង្ហាញយ៉ាងច្បាស់អំពីការជ្រោងខ្ពស់នៃ«ការអនុវត្តការទូតសភា»ដែលជាគោលការណ៍ប្រកបដោយចក្ខុវិស័យច្បាស់លាស់របស់ **សម្តេចតេជោ** សំដៅបណ្តុះនិងពង្រឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយស្ថាប័ន នីតិប្បញ្ញត្តិ នៃបណ្តាប្រទេសជាមិត្តនៅទូទាំងពិភពលោក ជាពិសេសជាមួយស្ថាប័ននីតិប្បញ្ញត្តិ នៃសាធារណរដ្ឋប្រជាមានិតចិន។ អំណោយដ៏ថ្លៃថ្លានេះ គឺលើសពីកាយវិការជាសុច្ឆន្ទៈ តែជាការបង្ហាញដ៏មានឥទ្ធិពលនៃមិត្តភាព កិច្ចសហការយ៉ាងស៊ីជម្រៅ ការប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់សុខភាពប្រជាជន និងជាសារដ៏មានអានុភាពឆ្លុះបញ្ចាំងអំពីភាពជាដៃគូពិត ពីភាពរឹងមាំនៃ «មិត្តភាពដែកថែប» រវាងកម្ពុជានិងចិន លើមូលដ្ឋានសាមគ្គីភាព ភាពជន់ទំនុកចិត្ត និងភាពយូរអង្វែងនៃទំនាក់ទំនងទ្វេភាគី៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីផ្តល់ជំនួយមនុស្សធម៌របស់មូលនិធិសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ជូនរដ្ឋបាលខេត្តកណ្តាល





*ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តម គួច ចំរើន អភិបាលខេត្តកណ្តាល*

នាព្រឹកថ្ងៃពុធ ទី១១ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ ឱសថ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ (Global Life Sharing) ជូនដល់រដ្ឋបាលខេត្តកណ្តាល ដឹកនាំដោយឯកឧត្តម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល នៅសាលាខេត្តកណ្តាល។

ពិធីប្រគល់-ទទួលនេះ ប្រព្រឹត្តទៅដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក សមាជិកាគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា(គណៈកម្មការទី១០) ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្តាល) ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត តំណាងមន្ទីរជំនាញពាក់ព័ន្ធ និងតំណាងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ។

ក្នុងឱកាសនោះ ឯកឧត្តម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល បានថ្លែងស្វាគមន៍យ៉ាងកក់ក្តៅ





*ទិដ្ឋភាពក្នុងពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ និងឱសថ*

ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ គណៈប្រតិភូព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកនិងមានតម្លៃ នាំយកនូវសម្ភារៈវេជ្ជសាស្ត្រ ឱសថ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ជូនដល់រដ្ឋបាលខេត្តកណ្តាល។ អំណោយមនុស្សធម៌នេះ ជាសក្ខីភាពនៃការគិតគូរយកចិត្តទុកដាក់យ៉ាងកក់ក្តៅពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ក្នុងការរួមចំណែកដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតនិងងាយរងគ្រោះនៅមូលដ្ឋានឱ្យបានប្រសើរឡើង។

មានប្រសាសន៍សំណេះសំណាលនាឱកាសនោះ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានជម្រាបជូននូវការសួរសុខទុក្ខដោយក្តីនឹករលឹកពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់ថ្នាក់ដឹកនាំខេត្តនិងបងប្អូនប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានខេត្តកណ្តាល។ ឯកឧត្តមបានគូសបញ្ជាក់ថា អំណោយមនុស្សធម៌ដែលយកមកជូនរដ្ឋបាលខេត្តកណ្តាល គឺជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងរបស់ព្រឹទ្ធសភា ក្រោមការដឹកនាំរបស់**សម្តេចតេជោប្រធានព្រឹទ្ធសភា** និងការអនុវត្តដោយយកចិត្តទុកដាក់របស់គណៈកម្មការទី១០ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៣ ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** បានស្វែងរកជំនួយឧបត្ថម្ភពីបណ្តាប្រទេសជាមិត្តបន្ថែមលើការងារស្នូលរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន ស្របនឹងទិសដៅការងារអាទិភាពចំនួន២ ដែល **សម្តេចតេជោប្រធានព្រឹទ្ធសភា** បានកំណត់ គឺការចុះសាកសួរសុខទុក្ខដល់ប្រជាពលរដ្ឋនិងអង្គបោះឆ្នោតក្នុងភូមិភាគរបស់ខ្លួន និងការអនុវត្តការទូតសភា។





*ទិដ្ឋភាពក្នុងពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ និងឱសថ*

យោងតាមអនុស្សរណៈនៃការយោគយល់រវាងគណៈកម្មការទី១០ព្រឹទ្ធសភា ជាមួយនឹងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ អំណោយមនុស្សធម៌ដែលប្រគល់ជូនដល់រដ្ឋបាលខេត្តកណ្តាលនាពេលនេះ មានទំហំទឹកប្រាក់ប្រមាណជា១លានដុល្លារអាម៉េរិក ហើយនឹងបន្តផ្តល់ជូនដល់រដ្ឋបាលខេត្តកណ្តាលបន្ថែមទៀត ក្នុងទំហំទឹកប្រាក់៤លានដុល្លារសហរដ្ឋអាម៉េរិក ចាប់ពីពេលនេះ រហូតដល់ឆ្នាំ២០២៩ សំដៅចូលរួមលើកកម្ពស់ជីវភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# សន្តិភាពត្រូវបានការពារដូចជាអាយុជីវិតរបស់យើង ហើយដែនដីត្រូវបានការពារដូចជាដួងព្រលឹងរបស់យើង



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលជាមួយ កងកម្លាំងការពារព្រំដែនតំបន់មុំបី*

«សន្តិភាពត្រូវបានការពារដូចជាអាយុជីវិតរបស់យើង ហើយដែនដីត្រូវបានការពារដូចជាដួងព្រលឹងរបស់យើង» ពាក្យពេចន៍ពីរឃ្លាដ៏ពិសិដ្ឋនិងមានអត្ថន័យដ៏ឧត្តុង្គឧត្តមថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** ដែលត្រូវបានចារទុកក្នុងទឹកចិត្តរបស់អ្នកស្នេហាជាតិគ្រប់រូប ត្រូវបានឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** រំឭកដល់កងកម្លាំងការពារព្រំដែនក្នុងខេត្តព្រះវិហារ នាថ្ងៃព្រហស្បតិ៍ ទី១២ ខែមិថុនា ឆ្នាំ២០២៥ ក្នុងឱកាសដែលគណៈប្រតិភូព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខនិងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ និងថវិកាមួយចំនួន ជូនដល់កងកម្លាំងជួរមុខការពារព្រំដែនក្នុងខេត្តព្រះវិហារ។





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលជាមួយកងកម្លាំងការពារព្រំដែនតំបន់មុំបីក្នុងខេត្តព្រះវិហារ*





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលជាមួយកងកម្លាំងការពារព្រំដែននៅកងពលតូចអន្តរាគមន៍លេខ៨*

ក្នុងពិធីសំណេះសំណាលនេះ មានការអញ្ជើញចូលរួមពីឯកឧត្តមបណ្ឌិត **ឆន់ ខឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា, សមាជិក សមាជិកាព្រឹទ្ធសភា, ទីប្រឹក្សា, ថ្នាក់ដឹកនាំនិងមន្ត្រីខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាច្រើននាក់។

ក្នុងឱកាសសំណេះសំណាលដាច់ដោយឡែកពីគ្នា ជាមួយកងកម្លាំងការពារព្រំដែន នៅកងពលតូចអន្តរាគមន៍លេខ៨ និងនៅទីបញ្ជាការដ្ឋានកងអង្គរក្សការពារព្រំដែនតំបន់មុំបី ខេត្តព្រះវិហារ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានមានប្រសាសន៍ថា «សន្តិភាព» មិនមែនជាអំណោយនោះទេ តែជាសមិទ្ធផលដែលទទួលបានដោយលំបាក តាមរយៈការបូជាទាំងកម្លាំងកាយ ចិត្ត និងការធ្វើពលិកម្មគ្រប់បែបយ៉ាងរបស់**សម្តេចតេជោ** ដោយមានការគាំទ្រយ៉ាងភ្លៀវក្លាពីសំណាក់បងប្អូនប្រជាពលរដ្ឋនៅទូទាំងប្រទេសនិងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីជាគុណប្រយោជន៍ដល់ការអភិវឌ្ឍប្រទេសជាតិរីកចម្រើនរហូតមកដល់ពេលបច្ចុប្បន្ន។ ដូចនេះ «ការការពារសន្តិភាព» ជាកាតព្វកិច្ចដែលបងប្អូនប្រជាពលរដ្ឋខ្មែរគ្រប់រូបរួមសាមគ្គីឯកភាពជាធ្លុងមួយការពារ ទោះក្នុងតម្លៃណាក៏ដោយ ដោយផ្សារភ្ជាប់នឹង «ការការពារដែនដីដូចជាដួងព្រលឹងរបស់យើង» ដែលជាមូលដ្ឋានគ្រឹះមិនអាចខ្វះបាននៃអត្តិភាពអត្តសញ្ញាណជាតិសាសន៍ វប្បធម៌ប្រពៃណី កម្មសិទ្ធិរបស់ជាតិនីមួយៗ។ កុំយល់ច្រឡំឱ្យសោះថា បំណងប្រាថ្នារបស់កម្ពុជាចង់បានសន្តិភាព មិនមែនមានន័យថា កម្ពុជាលះបង់សិទ្ធិអធិបតេយ្យក្នុងការការពារទឹកដីមាតុភូមិរបស់ខ្លួននោះទេ។ យុទ្ធជន យុទ្ធនារីដ៏អង់អាចក្លាហានដែលកំពុងឈរជើងនៅតាមបណ្តោយព្រំដែននេះ មិនមែនគ្រាន់តែជាយោធាប៉ុណ្ណោះទេ តែជានិមិត្តរូបនៃឯកភាពជាតិ សេចក្តីថ្លៃថ្នូរ និងការប្តេជ្ញាចិត្តរបស់បងប្អូនប្រជាពលរដ្ឋស្នេហាជាតិទាំងអស់នៅទូទាំងប្រទេស និងជាខែលការពារជាតិមាតុភូមិ ការពារព្រលឹងជាតិខ្មែរ ជាខែលការពារសន្តិភាព សន្តិសុខ សុវត្ថិភាព និងសេចក្តីសុខសាន្តរបស់ប្រទេសជាតិ។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា**បានបន្ថែមថា កម្ពុជាជាប្រជាជាតិមួយដែលស្រឡាញ់សន្តិភាព ចង់រួមរស់ដោយសន្តិសហវិជ្ជមាន និងពង្រឹងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយបណ្តាប្រទេសទាំងអស់នៅក្នុងពិភពលោកលើមូលដ្ឋាននៃការគោរពគ្នានិងមានផលប្រយោជន៍ទៅវិញទៅមក។ ការណ៍នេះមិនជាឧត្តមគតិអរូបីទេ ប៉ុន្តែជាផ្លែផ្កានៃមេរៀនដ៏ឈឺចាប់នៃប្រវត្តិសាស្ត្រ ដែលកម្ពុជាធ្លាប់បានឆ្លងកាត់អស់រយៈពេលជាងពីរទសវត្សរ៍នៅក្នុងភ្នក់ភ្លើងសង្គ្រាម និងរបបប្រល័យពូជសាសន៍។ កម្ពុជាយល់ច្បាស់ណាស់អំពីគុណតម្លៃសន្តិភាព។ ក្រោមការដឹកនាំដ៏ភ្លឺស្វាងប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ** និងប្រកបដោយថាមពលរបស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កម្ពុជានឹងបន្តស្វែងរកដំណោះស្រាយទំនាស់ដោយសន្តិវិធីឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញជាតិ ច្បាប់អន្តរជាតិ និងធម្មនុញ្ញអង្គការសហប្រជាជាតិ។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ជូនដល់នាយទាហាន នាយទាហានរង និងពលទាហាន ដែលកំពុងឈរជើងនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តព្រះវិហារ ត្រៀមប្រយុទ្ធការពារបូរណភាពដែនដីនៃមាតុភូមិកម្ពុជា និងបានគូសបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ **សម្តេចទាំងពីរ** ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ជាពិសេសសុខទុក្ខរបស់នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ដោយចាត់ទុកជាសុខទុក្ខផ្ទាល់របស់សម្តេច ព្រមទាំងបានសម្តែងនូវគារវកិច្ចកោតសរសើរនិងគោរពចំពោះវីរភាពអង់អាចក្លាហានរបស់វីរយុទ្ធជន ដែលបានធ្វើពលិកម្មទាំងកម្លាំងកាយ កម្លាំងចិត្ត និងអាយុជីវិត ដើម្បីប្រទេសជាតិ។

តាងនាម**សម្តេចតេជោប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ទីប្រឹក្សា ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានសម្តែងជាថ្មីម្តងទៀតនូវការគោរពនិងកោតសរសើរដ៏ជ្រាលជ្រៅចំពោះវីរភាពអង់អាចក្លាហានរបស់វីរយុទ្ធជននៃកងកម្លាំងប្រដាប់អាវុធទាំងអស់ និងបាននាំយកនូវអំណោយនិងវិភាគទានមួយចំនួនរបស់សម្តេចទាំងពីរ ជាមួយនឹងការចូលរួមវិភាគទានពីថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ទីប្រឹក្សា ខុទ្ទកាល័យថ្នាក់ដឹកនាំទាំងបី ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនដល់កងពលតូចអន្តរាគមន៍លេខ៨ និងកងអង្គរក្សការពារព្រំដែនតំបន់មុំបី ខេត្តព្រះវិហារ។

មុននឹងបញ្ចប់ពិធីសំណេះសំណាល **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានជូនពរ និងបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ដែលនៅរក្សាការពារប្រាសាទព្រះវិហារ សូមជួយថែរក្សាបងប្អូនវីរយុទ្ធជនទាំងអស់នៅគ្រប់សមរភូមិ និងសូមទទួលបាននូវជោគជ័យគ្រប់ភារកិច្ច វាយកម្ទេចពួកឈ្លានពាន ដែលបង្កការរំខានដល់សេចក្តីសុខ សន្តិភាព ដែលជាកេរដំណែលរបស់រដ្ឋបុរសជាតិ ជាស្ថាបនិកសន្តិភាព និងជាអគ្គមគ្គទេសក៍ឯកនៃនយោបាយឈ្នះ-ឈ្នះ, សម្តេចតេជោ **ហ៊ុន សែន**។

បន្ទាប់ពីពិធីខាងលើ គណៈប្រតិភូព្រឹទ្ធសភាបានបន្តអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី **សោ ឧទ្ធី** មេបញ្ជាការកងអនុសេនាតូចស៊ើបការណ៍វរសេនាតូចលេខ៣៩២ ខេត្តព្រះវិហារ ដែលបានទទួលមរណភាពកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ក្នុងជន្មាយុ៤៨ឆ្នាំ និងបានផ្តល់ថវិកាជួយឧបត្ថម្ភដល់គ្រួសារសពផងដែរ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី សោ ឧទ្ធី*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសមាជិកសមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០២៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងបរិវេណពហុកីឡដ្ឋានជាតិមរតកតេជោ។



❈នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌឹមហ៊ុយ** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅរាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃចន្ទ ទី២៣ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យសមាគមនិស្សិតប្រចាំសាធារណរដ្ឋប្រជាមានិតចិន (CUGB) ដឹកនាំដោយលោក Lin Shanyuan ចូលជួបសម្តែងការគួរសម នៅសាលពិសេស វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃពុធ ទី២៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសភាជាតិកម្ពុជា-APF និងជាអនុប្រធានសភាប្រើភាសាបារាំង (APF) បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមចូលរួមសម័យប្រជុំប្រចាំឆ្នាំ លើកទី៥០ នៃសភាប្រើភាសាបារាំង (APF) នៅប្រទេសបារាំង នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអនុញ្ញាតជូនលោកស្រីបណ្ឌិត **អេង នេត្រា** ប្រធានវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ចូលជួបដើម្បីសម្តែងការគួរសមនិងពិភាក្សាការងារ នៅសាលប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។



❈នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំជំរុញការងារស្រាវជ្រាវលើប្រធានបទសំខាន់ៗ ដូចជា សេដ្ឋកិច្ចសាមគ្គី សេដ្ឋកិច្ចព្រំដែន អាហារ និងការអប់រំកុមារ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានគណៈកម្មការពិសេស បានដឹកនាំកិច្ចប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យនិងពិភាក្សាលើការរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំជាមួយឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មការទាំង១០ ក្រុមសមាជិកភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងគណៈកម្មការក្រមសីលធម៌សភារបស់ព្រឹទ្ធសភា ដើម្បីរៀបចំផែនការសកម្មភាពតាមមូលដ្ឋានសម្រាប់ចន្លោះសម័យប្រជុំលើកទី៣ និងទី៤ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។




❈នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធី «ទិវាប្រទេសរុស្ស៊ី» នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ នៅភូមិកំពេញ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខ និងនាំយកថវិការបស់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យនិងនិស្សិត នៃសាកលវិទ្យាល័យរដ្ឋចំនួន២០ និងថវិការបស់ឯកឧត្តមបណ្ឌិត ជូនគ្រួសារសពលោកព្រឹន្ទបាលឯក **សួន រ៉ោន** ដែលបានទទួលមរណភាពក្នុងហេតុការណ៍ផ្ទុះអាវុធជាមួយទាហានថៃ នៅតំបន់ព្រំដែនមុំបី ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។



❈នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកម្មវិធីជួបជុំអតីតនិស្សិតមកពីសាកលវិទ្យាល័យ Nagoya ប្រទេសជប៉ុន នៅ Fairfield by Marriott Phnom Penh។



❈នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកម្មវិធីការដាក់ឱ្យប្រើប្រាស់បណ្ណាល័យ មេគង្គ-ឡានឆាង នៅក្នុងសាលាបឋមសិក្សាព្រែកលៀប។



❈នារសៀលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោកស្រីបណ្ឌិត Ratih D.Adiputri ដែលកំពុងធ្វើការស្រាវជ្រាវនៅសាកលវិទ្យាល័យ Jyvaskyla នៅប្រទេសហ្វាំងឡង់ ចូលជួបសម្តែងការគួរសម នៅបន្ទប់ប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សុខ ខា** អតីតអនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។



# គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាជាមួយក្លឹបអ្នកកាសែតកម្ពុជា ជុំវិញនយោបាយការទូតសភាកម្ពុជា

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានទទួលជួបពិភាក្សាជាមួយក្លឹបអ្នកកាសែតកម្ពុជា ដឹកនាំដោយ លោក **ពុយ គា** ប្រធានក្លឹបអ្នកកាសែតកម្ពុជា ស្ដីពីនយោបាយការទូតសភាកម្ពុជា នៅសាលសិក្ខាសាលា ខាងជើង វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ ដោយមានការចូលរួមពីអ្នកសារព័ត៌មានចំនួន៧០នាក់ មកពី៦០ស្ថាប័ន។

ជាកិច្ចចាប់ផ្ដើម លោក **ពុយ គា** ប្រធានក្លឹបអ្នកកាសែត បានឱ្យដឹងថា ការរៀបចំវេទិកាពិភាក្សានេះ គឺដើម្បីផ្ដល់ឱកាសដល់អ្នកសារព័ត៌មាន បានស្វែងយល់កាន់តែច្បាស់នូវ «នយោបាយការទូតសភាកម្ពុជា» ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្ដេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។ លោក **ពុយ គា** បានចាត់ទុកវេទិកានេះ ជាឱកាសដ៏កម្រដែលអ្នកសារព័ត៌មាន បានជួបពិភាក្សាដោយផ្ទាល់ជាមួយសមាជិកព្រឹទ្ធសភា ហើយអាចលើកជាសំណួរទាក់ទងនឹងនយោបាយការទូតសភា។ ទន្ទឹមនឹងនេះ វេទិកាពិភាក្សានេះ ក៏រៀបចំឡើងក្នុងពេលដែលកម្ពុជា កំពុងមានភាពតានតឹងជាមួយភាគីថៃ លើជម្លោះព្រំដែន។



*ឯកឧត្តមបណ្ឌិត ចែម វីឡា ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា*

មានប្រសាសន៍ក្នុងជំនួបពិភាក្សានោះ ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានគូសបញ្ជាក់ អំពីសារៈសំខាន់នៃនយោបាយការទូតសភា ដោយបានបញ្ជាក់ថា សភាការទូតជាសិល្បៈនៃការធ្វើទំនាក់ទំនងរស់រវើកពុំមានការចង ដែលផ្ដល់មូលដ្ឋានគ្រឹះដល់ការទូតរបស់រដ្ឋ ក្នុងការលើកកម្ពស់ការយោគយល់គ្នាទៅវិញទៅមក និងមិត្តភាព ដើម្បីការពារសមិទ្ធផលនយោបាយនិងសេដ្ឋកិច្ចរបស់ប្រទេសរៀងខ្លួន។

ឯកឧត្តមបណ្ឌិត **ចែម វីឡា** បានមានប្រសាសន៍ថា ព្រឹទ្ធសភានីតិកាលទី៥នេះ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោប្រធានព្រឹទ្ធសភា** បានដាក់ចេញនូវអាទិភាពចម្បងចំនួន២ គឺ៖ ១-សភាការទូត និង ២-ការធ្វើការជិតស្និទ្ធជាមួយអង្គបោះឆ្នោត។ អាទិភាពនេះ ជួយធានាដល់ការផ្លាស់ប្ដូររវេនរដ្ឋាភិបាលថ្មីឱ្យមានភាពរលូន ក្រោមសន្តិភាពនិងស្ថេរភាពនយោបាយក្នុងប្រទេសនិងក្រៅប្រទេស។ ស្ថានភាពពិភពលោកបច្ចុប្បន្នមានលក្ខណៈស្មុគស្មាញ ពហុប៉ូល និងគ្រោះថ្នាក់ ដោយសារតែការប្រកួតប្រជែងយុទ្ធសាស្ត្ររបស់មហាអំណាចពិភពលោក





*អ្នកសារព័ត៌មានកម្ពុជាចូលរួមក្នុងវេទិកាពិភាក្សាស្ដីពី នយោបាយការទូតសភាកម្ពុជា*




*ទិដ្ឋភាពក្នុងវេទិកាពិភាក្សាស្ដីពី នយោបាយការទូតសភាកម្ពុជា*

សង្គ្រាមនិងវិបត្តិនានា រួមទាំងការគំរាមកំហែងសន្តិសុខពិភពលោកមិនប្រពៃណី។ ក្នុងបរិបទអន្តរជាតិដ៏លំបាកបច្ចុប្បន្ននេះ **សម្ដេចតេជោប្រធានព្រឹទ្ធសភា** បានសង្កត់ធ្ងន់ថា ការពង្រឹងទំនាក់ទំនងជាមួយដៃគូអន្តរជាតិ និងការចូលរួមសកម្មក្នុងវេទិកាសកល គឺសំខាន់បំផុត។ កិច្ចសហការរវាងសភានានានៅក្នុងនិងក្រៅតំបន់ គឺបំពេញបន្ថែមលើសកម្មភាពរបស់រដ្ឋាភិបាល និងជាការរួមចំណែកយ៉ាងធំធេងដល់សន្តិភាព សន្តិសុខនិងវិបុលភាពពិភពលោក។

ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** បានជម្រាបអំពីភាពមមាញឹករបស់**សម្ដេចតេជោប្រធានព្រឹទ្ធសភា** ក្នុងការទទួលជួបពិភាក្សាការងារនៅកម្ពុជានិងនៅបរទេសជាមួយប្រមុខរដ្ឋ ថ្នាក់ដឹកនាំសភា រដ្ឋមន្ត្រី និងស្ថាប័នអន្តរជាតិនានាពីបណ្ដាប្រទេសជិតឆ្ងាយ។ ជាពិសេសការយកចិត្តទុកដាក់លើបញ្ហាមីយ៉ាន់ម៉ានិងអ៊ុយក្រែន ដោយបានជួបជាមួយថ្នាក់ដឹកនាំ និងបេសកជនពិសេសពីប្រទេសបារាំង ជប៉ុន មីយ៉ាន់ម៉ានិងអ៊ុយក្រែន( តាមប្រព័ន្ធនិម្មិត ) ដើម្បីស្វែងរកសន្តិភាព និងការរួបរួមជាតិនៅប្រទេសមីយ៉ាន់ម៉ាហើយពង្រឹងសន្តិភាពនិងសន្តិសុខរបស់សកលលោក។ **សម្ដេចតេជោប្រធានព្រឹទ្ធសភា** ក៏បានបំពេញទស្សនកិច្ចទៅប្រទេសវៀតណាម កូរ៉េ ចិន អារ៉ាប់ប៊ីសាអូឌីត កាតា ទួគីយ៉េ និងអេមីរេត អារ៉ាប់រួម ដែលជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ ដែលថ្នាក់ដឹកនាំកម្ពុជាបានធ្វើទស្សនកិច្ចនៅមជ្ឈិមបូព៌ា ហើយបានជួបជាមួយនឹងប្រមុខរដ្ឋ និងប្រមុខដឹកនាំសភាជាន់ខ្ពស់និងជាន់ទាប។ ហើយកាលពីពេលថ្មីៗនេះ នៅក្នុងដំណើរទស្សនកិច្ចផ្លូវការទៅកាន់ប្រទេសឥណ្ឌូណេស៊ីនិងប្រទេសទីម័រឡេស្ត **សម្ដេចតេជោប្រធានព្រឹទ្ធសភា** ត្រូវបានទទួលស្វាគមន៍យ៉ាងឧត្តុង្គឧត្តម ព្រមទាំងទទួលបាននូវគ្រឿងឥស្សរិយយសលំដាប់ខ្ពស់បំផុតពីប្រទេសទីម័រឡេស្តទៀតផង។

ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** បានគូសបញ្ជាក់អំពីភាពអព្យាក្រឹតរបស់កម្ពុជា យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ ទើប**សម្ដេចតេជោប្រធានព្រឹទ្ធសភា** កំណត់យ៉ាងច្បាស់លាស់នូវគោលនយោបាយការបរទេសកម្ពុជា ឯករាជ្យភាព អព្យាក្រឹតភាព ដោយផ្អែកលើច្បាប់ ជាពិសេសគឺច្បាប់អន្តរជាតិ ដែលរួមបញ្ចូលទាំងធម្មនុញ្ញអង្គការសហប្រជាជាតិនិងធម្មនុញ្ញអាស៊ាន។ **សម្ដេចតេជោប្រធានព្រឹទ្ធសភា** បានកំណត់នូវគោលការណ៍ «មិន» ទាំង៧៖ ទី១-មិនគាំទ្រការប្រើប្រាស់កម្លាំង ឬការគំរាមកំហែងប្រើប្រាស់កម្លាំងក្នុងទំនាក់ទំនងអន្តរជាតិ ទី២-មិនគាំទ្រការឈ្លានពានប្រឆាំងនឹងរដ្ឋឯករាជ្យអធិបតេយ្យ ទី៣-មិនគាំទ្រចលនាបំបែកខ្លួន ឬចលនាបំបែកបំបាក់ ទី៤-មិនគាំទ្រការរាទទឹដណ្ដើមយកទឹកដីរដ្ឋអធិបតេយ្យ ទី៥-មិនជ្រៀតជ្រែក ឬគាំទ្រសកម្មភាពណាមួយដែលជ្រៀតជ្រែក ក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ទី៦-មិនអនុញ្ញាតឱ្យមានវត្តមានមូលដ្ឋានយោធាបរទេសមួយនៅលើទឹកដីកម្ពុជា និងទី៧-មិនចូលបក្ខពួកជាមួយប្រទេសឬក្រុមណាមួយប្រឆាំងនឹងប្រទេស ឬក្រុមផ្សេងទៀតឡើយ៕

*អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន*



*គណៈកម្មការទី៥ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយក្លឹបអ្នកកាសែតកម្ពុជា*

# ឯកឧត្តម ម៉ម ប៊ុននាង នាំយកអំណោយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េប្រគល់ជូនរដ្ឋបាលខេត្តកំពង់ស្ពឺ



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា*



*ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលខេត្តកំពង់ស្ពឺ*

នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ គណៈប្រតិភូគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយនៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** បាននាំយកអំណោយមនុស្សធម៌មានដូចជាសម្ភារៈវេជ្ជសាស្ត្រ ឱសថ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ (Global Life Sharing) ប្រគល់ជូនរដ្ឋបាលខេត្តកំពង់ស្ពឺ នៅសាលាខេត្តកំពង់ស្ពឺ។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ជាម ច័ន្ទសោភ័ណ** អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **ម៉ម ប៊ុននាង** និងគណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ព្រមទាំងតំណាងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ដែលបាននាំយកអំណោយមនុស្សធម៌ដ៏ថ្លៃថ្លា និងមានសារៈសំខាន់បំផុត សម្រាប់ចូលរួមជួយលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះនៅមូលដ្ឋានខេត្តកំពង់ស្ពឺឱ្យបានកាន់តែប្រសើរឡើង។

**ឯកឧត្តមអភិបាលខេត្ត** បានមានប្រសាសន៍ថា វត្តមានរបស់គណៈប្រតិភូពិតជាបង្ហាញឱ្យឃើញច្បាស់អំពីការយកចិត្តទុកដាក់ខ្ពស់ដល់សុខទុក្ខរបស់ប្រជាជនតាមជនបទ ព្រមទាំងសបញ្ជាក់ឱ្យឃើញពីការគោរពស្រលាញ់ និង





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា និងអាជ្ញាធរខេត្តកំពង់ស្ពឺ*

ការលើកទឹកចិត្តដល់មន្ត្រីរាជការ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងរួបរួមសាមគ្គីគ្នា បំពេញភារកិច្ចជូនជាតិមាតុភូមិកម្ពុជា ជាពិសេសបានរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់សុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋគ្រប់មូលដ្ឋានឱ្យកាន់តែប្រសើរ។ អំណោយមនុស្សធម៌ដ៏មានតម្លៃនេះ រដ្ឋបាលខេត្តកំពង់ស្ពឺនឹងចែកជូនដល់មន្ទីរពេទ្យបង្អែកខេត្ត មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ប្រកបដោយគណនេយ្យភាព តម្លាភាព និងស័ក្តិសិទ្ធិភាពស្របតាមបំណងប្រាថ្នារបស់គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយនៃព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ។


*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា និងអាជ្ញាធរខេត្តកំពង់ស្ពឺ*

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បានជម្រាបជូននូវការផ្តាំផ្ញើការសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំខេត្ត និងប្រជាពលរដ្ឋទាំងអស់នៃខេត្តកំពង់ស្ពឺ។ **ឯកឧត្តម** បានបញ្ជាក់ថា ក្រោមកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងគណៈកម្មការទី១០ព្រឹទ្ធសភា ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ អំណោយមនុស្សធម៌យ៉ាងច្រើនពីប្រជាជនកូរ៉េ តាមរយៈមូលនិធិចែករំលែកសង្គ្រោះជីវិតសកលជូនដល់ប្រជាពលរដ្ឋកម្ពុជា គិតមកដល់ពេលនេះមានទំហំទឹកប្រាក់ជាង១០លានដុល្លារសហរដ្ឋអាម៉េរិក ហើយនឹងជួយជាបន្តបន្ទាប់ទៀត ជាពិសេសសម្រាប់ខេត្តកំពង់ស្ពឺ ក្នុងទំហំទឹកប្រាក់៥លានដុល្លារសហរដ្ឋអាម៉េរិក ចាប់ពីពេលនេះរហូតដល់ឆ្នាំ២០២៩។

ជាមួយគ្នានោះ ឯកឧត្តម **ម៉ម ប៊ុននាង** បានថ្លែងអំណរគុណនិងកោតសរសើរចំពោះ**ឯកឧត្តមបណ្ឌិត អភិបាល**នៃគណៈអភិបាលខេត្ត និងសហការី ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ក្នុងខេត្តកំពង់ស្ពឺ ដែលបានយកចិត្តទុកដាក់ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន






*ឯកឧត្តម ម៉ម ប៊ុននាង ប្រគល់អំណោយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េជូនរដ្ឋបាលខេត្តកំពង់ស្ពឺ*

# គណៈកម្មការទី១០ព្រឹទ្ធសភា ធ្វើបច្ចុប្បន្នភាពអនុស្សរណៈយោគយល់គ្នា ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ដើម្បីនាំយកជំនួយមនុស្សធម៌ជូនដល់ប្រជាជននៅខេត្តតាកែវ និងខេត្តកំពត



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា*

នាព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយនៃព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** បានអញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម **គីម ជុងណាម** (KIM JUNG NAM) ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ (Global Life Sharing) ក្នុងឱកាសដែល**ឯកឧត្តម** ដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី២២ ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥។

ឯកឧត្តម **ម៉ម ប៊ុននាង** និងឯកឧត្តម **គីម ជុងណាម** បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី ការផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភាកម្ពុជា បន្ថែមលើអនុស្សរណៈដែលបានធ្វើលើកទី១ នៅឆ្នាំ២០២២ និងលើកទី២ នៅឆ្នាំ២០២៤។ អនុស្សរណៈបន្ថែមថ្មីនេះ រៀបចំឡើងដើម្បីផ្តល់ជំនួយមនុស្សធម៌ ដែលមានជា៖ ឱសថ ឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃសម្រាប់ជូនដល់រដ្ឋបាលខេត្តតាកែវ និងខេត្តកំពត ក្នុងទំហំទឹកប្រាក់ចំនួន១០លានដុល្លារអាម៉េរិក សម្រាប់រយៈពេល៥ឆ្នាំ ដើម្បីចូលរួមលើកកម្ពស់សុខភាព ការអប់រំ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ នៃខេត្តទាំងពីរឱ្យកាន់តែប្រសើរឡើង។

ឯកឧត្តម **ម៉ម ប៊ុននាង** បានគូសបញ្ជាក់ថា កិច្ចជំនួបពិភាក្សាការងារនិងការចុះអនុស្សរណៈបន្ថែម ជាការបោះជំហានថ្មីមួយទៀតសម្រាប់ព្រឹទ្ធសភាកម្ពុជាជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ក្នុងការរួមចំណែកលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋខេត្តតាកែវ និងខេត្តកំពត។ ឯកឧត្តមបានរំលឹកអំពីកិច្ចសហប្រតិបត្តិការនាពេលកន្លងទៅថា ចាប់តាំងពីឆ្នាំ២០២២ រហូតមកដល់ពេលនេះ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល បានផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភាកម្ពុជាចំនួន១០លើករួចមកហើយ ក្នុងទំហំទឹកប្រាក់ប្រមាណជាង ១០លានដុល្លារអាម៉េរិក។ ជំនួយមនុស្សធម៌ទាំងអស់ ត្រូវបានបែងចែកស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យជ័យវរ្ម័នទី៧ អាដ្ឋាធរ និងមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តព្រៃវែង រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តព្រះសីហនុ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ តាមរយៈការគ្រប់គ្រងនិងការបែងចែកជំនួយប្រកបដោយតម្លាភាព





*ទិដ្ឋភាពក្នុងជំនួបរវាងគណៈកម្មការទី១០ព្រឹទ្ធសភា ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ*



ឯកឧត្តម គីម ជុងណាម (KIM JUNG NAM) ប្រធានមូលនិធិ
ចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ



ទិដ្ឋភាពក្នុងជំនួបរវាងគណៈកម្មការទី១០ព្រឹទ្ធសភា
ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ

និងគណនេយ្យភាព មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េក៏បានផ្តល់ជំនួយមនុស្សធម៌បន្ថែមដល់ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម ដោយក្នុងមួយខេត្តទទួលបានជំនួយមនុស្សធម៌ក្នុងទំហំទឹកប្រាក់៥លានដុល្លារអាម៉េរិក សម្រាប់រយៈពេល៥ឆ្នាំ (២០២៤-២០២៩)។

ក្នុងនាមព្រឹទ្ធសភាកម្ពុជា ឯកឧត្តម **ម៉ម ប៊ុននាង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **គីម ជុងណាម** និងសហការី ជាពិសេសមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េដែលបានខិតខំប្រឹងប្រែងកៀរគរជំនួយមនុស្សធម៌ពីប្រជាជនកូរ៉េ មកជួយឧបត្ថម្ភគាំទ្រដល់ប្រជាជនកម្ពុជា សំដៅរួមចំណែកលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជនខ្សត់ខ្សោយនិងជនងាយរងគ្រោះ ដូចជា កុមារ មនុស្សចាស់ជរា និងជនមានពិការភាពឱ្យបានកាន់តែប្រសើរឡើង។

ឯកឧត្តម **គីម ជុងណាម** បានវាយតម្លៃខ្ពស់ចំពោះសកម្មភាពរបស់មូលនិធិនាពេលកន្លងទៅនិងបានគូសបញ្ជាក់ថា អំណោយមនុស្សធម៌លើកទី១១ បានវេចខ្ចប់រួចរាល់ហើយ នឹងបញ្ជូនមកព្រឹទ្ធសភាកម្ពុជាឆាប់ៗ។ **ឯកឧត្តម** មានជំនឿថា នៅក្នុងឆ្នាំ២០២៥ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នឹងរៀបចំជំនួយមនុស្សធម៌មកកាន់ព្រឹទ្ធសភាកម្ពុជាចំនួន៤លើកបន្ថែមទៀត។

បន្ថែមពីលើកិច្ចសហប្រតិបត្តិការដែលមានស្រាប់ នាពេលអនាគត មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនឹងបង្កើនជំនួយក្នុងទំហំទឹកប្រាក់១០លានដុល្លារអាម៉េរិកជារៀងរាល់ឆ្នាំ។ ក្រៅពីនេះ មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនឹងរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលដល់ក្រុមគ្រូពេទ្យកម្ពុជាថែមទៀត។

ឯកឧត្តម **ម៉ម ប៊ុននាង** និងឯកឧត្តម **គីម ជុងណាម** បានប្តេជ្ញាពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការការងារឱ្យកាន់តែសកម្ម កាន់តែប្រសើរ ដើម្បីចែករំលែកក្តីស្រឡាញ់ តាមរយៈសកម្មភាពមនុស្សធម៌ ចូលរួមដោះស្រាយការខ្វះខាតក្នុងវិស័យសុខាភិបាល ការអប់រំផ្នែកវេជ្ជសាស្ត្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនកម្ពុជាឱ្យកាន់តែប្រសើរ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





គណៈកម្មការទី១០ព្រឹទ្ធសភា ចុះអនុស្សរណៈយោគយល់គ្នាជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ និងថតរូបអនុស្សាវរីយ៍

# ក្រុមសមាជិកាព្រឹទ្ធសភា ជួបពិភាក្សានិងស្តាប់បទបង្ហាញរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីប្រមូលធាតុចូលសម្រាប់សមាជិកព្រឹទ្ធសភាបំពេញមុខងារតំណាង ឱ្យកាន់តែមានប្រសិទ្ធភាព

នាព្រឹកថ្ងៃចន្ទ ទី២៣ ខែមិថុនា ឆ្នាំ២០២៥ ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សា និងស្តាប់បទបង្ហាញស្តីពី ទិដ្ឋភាព នៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដឹកនាំដោយឯកឧត្តម **សយ កុសល** ប្រធានសម្ព័ន្ធភាពជាតិ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។



*លោកជំទាវ មាន សំអាន ប្រធានក្រុមសមាជិកាព្រឹទ្ធសភា*

ក្នុងឱកាសនោះ លោកជំទាវ **មាន សំអាន** បានចូលរួមអបអរសាទរចំពោះ ឯកឧត្តម លោក លោកស្រី ដែលអង្គសន្និបាតបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តជ្រើសតាំងធ្វើជាប្រធាន អនុប្រធាន និងសមាជិកនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដែលជាអង្គអភិបាលកិច្ចសម្រាប់ដឹកនាំសមាគម ក្នុងអាណត្តិទី៤។ រាជរដ្ឋាភិបាលបានទទួលស្គាល់តួនាទីដ៏មានសារៈសំខាន់របស់សម្ព័ន្ធភាពជាតិ នៅក្នុងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលកន្លងមកបានធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំង២៥ រាជធានី ខេត្ត។



លោកជំទាវ **មាន សំអាន** បានជម្រាបអំពីគោលបំណងនៃជំនួបពិភាក្សា គឺដើម្បី៖ ១-បំពេញមុខងារអាទិភាពចម្បងទីពីរ (មុខងារតំណាង) ដើម្បីឆ្លើយតបចំពោះតម្រូវការ





*សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញស្តាប់បទបង្ហាញរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន*





*លោកជំទាវ មាន សំអាន មានប្រសាសន៍ក្នុងអង្គពិធី*

របស់ប្រជាពលរដ្ឋប្រកបដោយគុណភាព តម្លាភាព គណនេយ្យភាព និងជឿទុកចិត្ត ២-ប្រមូលផ្តុំធាតុចូលដែលជាតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលសម្ព័ន្ធភាពបានប្រមូល ចងក្រង ដើម្បីឱ្យសមាជិកា សមាជិកព្រឹទ្ធសភាបំពេញមុខងារតំណាងចំពោះអង្គបោះឆ្នោតកាន់តែមានប្រសិទ្ធភាព ៣-ចូលរួមលើកកម្ពស់សមភាពយេនឌ័រ លើកកម្ពស់ស្រ្តីក្នុងវិស័យនយោបាយ បង្កើនភាពអង់អាចដល់ស្ត្រីនិងបរិយាបន្ន នៅក្នុងរបៀបវារៈកំណើនសេដ្ឋកិច្ច កិច្ចគាំពារសង្គម និងអភិបាលកិច្ចល្អ ៤-បង្កើនភាពស្និទ្ធស្នាលនិងផ្លាស់ប្តូរបទពិសោធរវាងសមាជិកា សមាជិកព្រឹទ្ធសភា ជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

ឯកឧត្តម **សយ កុសល** ប្រធានសម្ព័ន្ធភាពជាតិ បានធ្វើបទបង្ហាញពីសាវតារ គោលបំណង ទិសដៅ រចនាសម្ព័ន្ធ ប្រភពធនធាន ការសហការ និងការគាំទ្រពីស្ថាប័នព្រឹទ្ធសភា ផែនការយុទ្ធសាស្ត្រ សកម្មភាពសំខាន់ៗ និងបញ្ហាប្រឈម ព្រមទាំងសំណូមពរ នៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

ក្នុងឱកាសនោះផងដែរ លោកស្រី **អាត សុខុម** អនុប្រធានសម្ព័ន្ធភាពជាតិ ក៏បានធ្វើបទបង្ហាញស្តីពី ការលើកកម្ពស់ស្រីនៅក្នុងវិស័យនយោបាយនៅមូលដ្ឋាន ដោយបានបង្ហាញអំពីការអនុវត្តគម្រោង PMI-WILL គាំទ្រក្នុងការលើកកម្ពស់ស្ត្រីនៅក្នុងវិស័យនយោបាយនៅមូលដ្ឋាន។ ការអនុវត្តគម្រោង PMI-WILL មានសារៈសំខាន់ណាស់ក្នុងការស្វែងយល់ពីទស្សនាទានយេនឌ័រ ផ្តល់ផ្នត់គំនិតសង្គម និងការដោះស្រាយវិសមភាពយេនឌ័រក្នុងគ្រួសារ ជាពិសេសជួយក្នុងការបង្កើនសមត្ថភាពស្ត្រីជាអ្នកដឹកនាំក្នុងការអនុវត្តអភិបាលកិច្ចល្អផងដែរ។

ជាចុងក្រោយ លោកជំទាវ **មាន សំអាន** បានថ្លែងនូវអំណរគុណដល់វាគ្មិន ក៏ដូចជាសមាជិក សមាជិកាព្រឹទ្ធសភា ដែលបានចូលរួមផ្តល់ជាអនុសាសន៍ដ៏ល្អៗ។ ទន្ទឹមគ្នានោះ **លោកជំទាវ** បានធ្វើការចាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី អំពើហិង្សាក្នុងគ្រួសារ ដែលបច្ចុប្បន្នអំពើហិង្សាមានការវិវត្ត ហើយណាមួយច្បាប់នេះ បានរៀបចំនិងប្រកាសឱ្យប្រើជាយូរមកហើយ គួរតែមានការធ្វើវិសោធនកម្មច្បាប់នេះ ឱ្យសមស្របស្ថានភាពបច្ចុប្បន្ន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ក្រុមសមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន*

# ឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញទទួលស្វាគមន៍ និងធ្វើបទបង្ហាញ ជូនប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន មកទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភាកម្ពុជា

នាព្រឹកថ្ងៃសុក្រ ទី៣០ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា(គណៈកម្មការទី១០) តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានអញ្ជើញទទួលស្វាគមន៍និងបទធ្វើបង្ហាញស្តីពី តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភាកម្ពុជា ជូនប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន ចំនួន៤៥នាក់ ក្នុងឱកាសអញ្ជើញមកទស្សនកិច្ចសិក្សាស្វែងយល់អំពី ព្រឹទ្ធសភាកម្ពុជា នៅវិមានព្រឹទ្ធសភា។



ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា

នៅក្នុងឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បានជម្រាបអំពីសាវតារ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា។ ព្រឹទ្ធសភានីតិកាលទី១ ចាប់បដិសន្ធិដោយការចាត់តាំង បានចាប់ដំណើរការកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។ ចាប់ពីនីតិកាលទី២ ព្រឹទ្ធសភាកើតឡើងតាមរយៈការបោះឆ្នោតជ្រើសតាំងជាអសកលមិនចំពោះ តាមវិធីជ្រើសរើសដោយបោះឆ្នោតជាសម្ងាត់។ ព្រឹទ្ធសភាមានសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភា២រូបចាត់តាំងដោយព្រះមហាក្សត្រ ២រូបជ្រើសតាំងដោយរដ្ឋសភា ក្រៅពីនេះសមាជិកចំនួន៥៨រូប ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាអសកល។ អាណត្តិរបស់ព្រឹទ្ធសភាមានរយៈពេល៦ឆ្នាំ។

ឯកឧត្តម **ម៉ម ប៊ុននាង** បានមានប្រសាសន៍បន្តថា ព្រឹទ្ធសភានីតិកាលទី៥ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** ជាអនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** ជាអនុប្រធានទី២ព្រឹទ្ធសភា។ ព្រឹទ្ធសភាមានមុខងារស្នូលចំនួន៣ គឺមុខងារនីតិកម្ម មុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់។ បន្ថែមពីនេះ ព្រឹទ្ធសភាមានមុខងារគាំទ្រចំនួន២ទៀត គឺមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។ ក្នុងរចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា រួមមាន៖ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការ





ប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន មកទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភាកម្ពុជា





*ឯកឧត្តម ម៉ម ប៊ុននាង ធ្វើបទបង្ហាញអំពីព្រឹទ្ធសភាកម្ពុជា ជូនប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន*

ទាំង១០របស់ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមពិភាក្សា) និងក្រុមយន្តការមួយចំនួនទៀត។

បន្ថែមពីនេះ ឯកឧត្តម **ម៉ម ប៊ុននាង** បានរំលេចអំពីតួនាទីដ៏សំខាន់របស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលការងាររវាងរដ្ឋសភានិងរាជរដ្ឋាភិបាល ដើម្បីដោះស្រាយរាល់វិបត្តិនយោបាយដែលកើតមានជាយថាហេតុ។ ទន្ទឹមគ្នានោះ ព្រឹទ្ធសភាមានការទទួលខុសត្រូវខ្ពស់ក្នុងភាពជាតំណាងការពារផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាជន ដោយធានាថា សំឡេងរបស់គាត់ត្រូវបានគោរពនៅក្នុងដំណើរការតាក់តែងច្បាប់ សេចក្ដីសម្រេចនានា ដែលឆ្លុះបញ្ចាំងអំពីគុណតម្លៃ និងបំណងប្រាថ្នារបស់សង្គមជាតិ និងប្រជាពលរដ្ឋ។



*ឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន*

បន្ទាប់ពីចូលស្ដាប់ការធ្វើបទបង្ហាញរួចមក ប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភានិងអគារប្រវត្តិសាស្ត្រនានា នៅក្នុងបរិវេណវិមានព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន






*ប្រតិភូសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន អញ្ជើញទស្សនាអគារ សាលប្រជុំព្រឹទ្ធសភា*

# សាស្ត្រាចារ្យ និស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដាចំនួន១០០នាក់ ទស្សនកិច្ចសិក្សាស្វែងយល់អំពីព្រឹទ្ធសភា


ឯកឧត្តម ម៉ែន-ស៊ីផាន់ អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា

ក្នុងឱកាសសាស្ត្រាចារ្យនិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ចំនួន១០០នាក់ អញ្ជើញទស្សនកិច្ចសិក្សាស្វែងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញធ្វើបទបង្ហាញស្តីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

ឯកឧត្តម **ម៉ែន-ស៊ីផាន់** បានបង្ហាញអំពីសារៈសំខាន់របស់ព្រឹទ្ធសភា រួមមាន៖ ១-សាវតារនៃការបង្កើតព្រឹទ្ធសភា ២-រចនាសម្ព័ន្ធព្រឹទ្ធសភា ៣-តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា។ ព្រឹទ្ធសភានីតិកាលទី១ ចាប់បដិសន្ធិដោយការចាត់តាំង បានចាប់ដំណើរការកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។ ចាប់ពីនីតិកាលទី២ ព្រឹទ្ធសភាកើតឡើងតាមរយៈការបោះឆ្នោតជ្រើសតាំងជាអសកល មិនចំពោះ តាមវិធីជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់។ ព្រឹទ្ធសភាមានសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល សមាជិកព្រឹទ្ធសភា២រូបចាត់តាំងដោយព្រះមហាក្សត្រ ២រូបជ្រើសតាំងដោយរដ្ឋសភា ក្រៅពីនេះសមាជិកចំនួន៥៨រូប ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាអសកល។ អាណត្តិរបស់ព្រឹទ្ធសភាមានរយៈពេល៦ឆ្នាំ។

ឯកឧត្តម **ម៉ែន-ស៊ីផាន់** បានរំលេចអំពីតួនាទីនយោបាយដ៏សំខាន់របស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលការងាររវាងរដ្ឋសភានិងរាជរដ្ឋាភិបាល ដើម្បីដោះស្រាយរាល់វិបត្តិនយោបាយ ដែលកើតមានជាយថាហេតុ។ ព្រឹទ្ធសភាមានភារកិច្ចទទួលខុសត្រូវខ្ពស់ក្នុងការធ្វើជាតំណាង និងការពារផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាជន ព្រមទាំងធានាថា សំឡេងរបស់គាត់ត្រូវបានគោរពនៅក្នុងដំណើរការតាក់តែងច្បាប់នានា។ ជាមួយគ្នានោះ ព្រឹទ្ធសភាក៏មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យតុល្យភាពនៃអំណាចរដ្ឋ ដោយធានាថា សេចក្តីសម្រេចនានា ត្រូវបានធ្វើឡើងដោយឆ្លុះបញ្ចាំងពីគុណតម្លៃ និងបំណងប្រាថ្នារបស់សង្គមជាតិនិងប្រជាពលរដ្ឋ។





ឯកឧត្តម ម៉ែន-ស៊ីផាន់ ធ្វើបទបង្ហាញអំពីព្រឹទ្ធសភាកម្ពុជា ជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដា




*សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដា ស្តាប់បទបង្ហាញអំពីព្រឹទ្ធសភាកម្ពុជា*

ព្រឹទ្ធសភានីតិកាលទី៥ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា។ ឯកឧត្តមបានគូសបញ្ជាក់ថា សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានីតិកាលទី៥ បានកំណត់ការងារអាទិភាពចម្បងចំនួន២ គឺ ១-ការអភិវឌ្ឍទំនាក់ទំនងអន្តរជាតិ តាមរយៈការលើកកម្ពស់ការទូតសភា ២-ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គបោះឆ្នោត នៃក្រុមប្រឹក្សាឃុំ សង្កាត់ ដែលតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន។

ក្នុងឱកាសនោះផងដែរ ក៏មានការធ្វើបទបង្ហាញអំពី ដំណើរការការងារនីតិកម្មរបស់ព្រឹទ្ធសភា ដោយលោក **សុខ សុជាតិ** ប្រធានក្រុមស្រាវជ្រាវទូទៅ នៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងបទបង្ហាញអំពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយលោកស្រី **ឃុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស។



ក្រោយពីបានស្តាប់ការធ្វើបទបង្ហាញរួចមក សាស្ត្រាចារ្យ និងនិស្សិតទាំងអស់ បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានា នៅក្នុងបរិវេណវិមានព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដា អញ្ជើញទស្សនាអគារនានាក្នុងបរិវេណព្រឹទ្ធសភា*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមតូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

### ❈កិច្ចប្រជុំក្រុមសមាជរដ្ឋសភានិងព្រឹទ្ធសភា (ក្រុមទី១) ចំនួន១លើក



នារសៀលថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **ឱ ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំក្រុមសមាជរដ្ឋសភានិងព្រឹទ្ធសភា (ក្រុមទី១) ដើម្បីពិភាក្សាលើ៖

១-ប្រធានបទអំពីប្រព័ន្ធគាំពារសង្គម ប្រធានបទអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងប្រធានបទអំពីវិស័យកសិកម្ម

២-ចាត់តាំងតំណាងក្រុម ដើម្បីមានមតិនៅពេលប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា នាពេលខាងមុខ

៣-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន១លើក



នាព្រឹកថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើ៖

១-ស្តាប់បទបង្ហាញការងារស្រាវជ្រាវ

២-ពិនិត្យរបាយការណ៍ប្រចាំខែ

៣-ពិនិត្យពិភាក្សាសេចក្តីព្រាងច្បាប់ទាំង២៤

៤-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន១លើក



នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការនានានៃព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ ឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនី ចំនួន២៤គម្រោង នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ចំនួន១លើក



នារសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១)

បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ដើម្បី៖

១-ស្តាប់បទបង្ហាញរបស់អគ្គនាយកដ្ឋានស្រាវជ្រាវ លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនីចំនួន២៤គម្រោង

២-ពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនីចំនួន២៤គម្រោង

៣-ពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ផលផល។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៣ព្រឹទ្ធសភា ចំនួន២លើក**

ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥។

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ផលផល នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥។

**❈កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន២លើក**



ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំរវាងគណៈកម្មការនានានៃព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ ឯកឧត្តម **ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥។



-កិច្ចប្រជុំរវាងគណៈកម្មការនានានៃព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ផលផល នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥។

**❈កិច្ចប្រជុំក្រុមសមាជរដ្ឋសភានិងព្រឹទ្ធសភា (ក្រុមទី២) ចំនួន១លើក**



នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំក្រុមសមាជិកសមាជព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យពិភាក្សាលើ៖

១-ប្រធានបទអំពីប្រព័ន្ធគាំពារសង្គម ប្រធានបទអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងប្រធានបទអំពីវិស័យកសិកម្ម

២-ចាត់តាំងតំណាងក្រុម ដើម្បីមានមតិនៅពេលប្រជុំ សមាជរដ្ឋសភានិងព្រឹទ្ធសភា នាពេលខាងមុខ

៣-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន១លើក**



នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-ការបូកសរុបរបាយការណ៍សកម្មភាពប្រចាំខែឧសភា ឆ្នាំ២០២៥

២-ជំនួបពិភាក្សារវាងគណៈកម្មការទី៥ និងក្លឹបអ្នកកាសែតកម្ពុជា នៅថ្ងៃ១៩ ខែមិថុនា ឆ្នាំ២០២៥

៣-ពិនិត្យ ពិភាក្សាគម្រោងចុះបេសកកម្មនៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥

៤-ការបូកសរុបចំណូល-ចំណាយប្រចាំខែឧសភា ឆ្នាំ២០២៥

៥-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ចំនួន២លើក**

ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) នារសៀលថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ដើម្បីពិនិត្យពិភាក្សានិងត្រៀមយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា

២-បញ្ហាផ្សេងៗ។



-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) នារសៀលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ ដើម្បីពិនិត្យពិភាក្សានិងត្រៀមយោបល់ក្នុងសម័យប្រជុំលើកទី៣ ព្រឹទ្ធសភា នីតិកាលទី៥ លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ជលផល

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនីចំនួន២៤គម្រោង។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៦ព្រឹទ្ធសភា ចំនួន២លើក**

លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នារសៀលថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ ដើម្បីពិនិត្យពិភាក្សាលើ៖



១-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា

២-ការចូលរួមសមាជរដ្ឋសភានិងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

៣-បញ្ហាផ្សេងៗ។




-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នារសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ដើម្បីពិនិត្យពិភាក្សាលើ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យបណ្ដាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនី ចំនួន២៤គម្រោង

២-សេចក្ដីព្រាងច្បាប់ស្ដីពី ជលផល

៣-គម្រោងចុះបំពេញបេសកកម្មរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា ចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥

៤-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំក្រុមសមាជរដ្ឋសភានិងព្រឹទ្ធសភា (ក្រុមទី៣) ចំនួន១លើក



នារសៀលថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិភាក្សាទៅលើខ្លឹមសារនៃបទអន្តរាគមន៍ និងបញ្ហាផ្សេងៗ នៅសាលប្រជុំពិសេស៣ព្រឹទ្ធសភា។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន១លើក

នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-ការស្ដាប់របាយការណ៍ស្ដីពី លទ្ធផលការងាររបស់



គណៈកម្មការប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២៥

២-ឯកសារជំនួយស្មារតីសម្រាប់ត្រៀមជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្ត មន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យសមត្ថកិច្ច នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង

៣-បញ្ហាផ្សេងៗ។

### ❈គណៈកម្មការទី៧ព្រឹទ្ធសភា ជួបភ្ញៀវជាតិ ចំនួន១លើក



នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ បានអនុញ្ញាតឱ្យក្រុមប្រឹក្សាបណ្ដាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា ដឹកនាំដោយ លោក **អ៊ឹង យូហាន** និងសហការី ចូលជួបសម្ដែងការគួរសម និងសុំអនុសាសន៍ដឹកនាំអំពីកិច្ចការសាសនា ក៏ដូចជាគ្រីស្ទសាសនា។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន២លើក

លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីបូកសរុបលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែឧសភា ឆ្នាំ២០២៥ និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៥ ព្រមទាំងបញ្ហាផ្សេងៗ នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីបោះឆ្នោតជ្រើសតាំងលេខាធិការគណៈកម្មការជំនួសឯកឧត្តម **ទេព យុទ្ធី** ដែលបានទទួលមរណភាព នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) ចំនួន២លើក

❈លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ដើម្បីពិនិត្យពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា

២-បញ្ហាផ្សេងៗ។



-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនីចំនួន២៤ច្បាប់ និងបញ្ហាផ្សេងៗ នារសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភា ចំនួន៤លើក

លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា បាន៖

-ដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ដើម្បីត្រៀមរៀបចំសន្និបាតរបស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥។



-ជួបពិភាក្សាការងារ និងស្តាប់បទបង្ហាញស្តីពីការស្រាវជ្រាវអង្កេតនិងវិភាគរបស់សមាគមសហគ្រិនស្ត្រីកម្ពុជា ពាក់ព័ន្ធនឹងស្ត្រី នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥។



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ដើម្បីពិភាក្សាលើ៖

១-ការត្រៀមស្មារតីចូលរួមសមាជរដ្ឋសភានិងព្រឹទ្ធសភា

២-ផែនការចុះបេសកកម្មស្រាវជ្រាវតាមបណ្តាឃុំ សង្កាត់ ក្នុងភូមិភាគទី៧ (ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ)

៣-បញ្ហាផ្សេងៗ



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភាជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ដើម្បីពិភាក្សាលើ៖

១-របាយការណ៍សង្ខេបអំពីលទ្ធផលមហាសន្និបាតអាណត្តិទី៤ របស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងបទបង្ហាញអំពី តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់៖

-សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬហៅថាសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

-សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅតាមរាជធានីខេត្ត ឬហៅថាសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានថ្នាក់រាជធានី ខេត្ត

-គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។

២-ការអនុវត្តលើកកម្ពស់សមភាពយេនឌ័រនៅថ្នាក់មូលដ្ឋាន ដោយផ្តោតលើមូលនិធិសេវាសង្គម

៣-ផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន១លើក**

នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិភាក្សាលើ៖



១-ដំណើរបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥។

២-ផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ចំនួន១លើក**

នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ដើម្បីពិភាក្សាលើ៖



១-ការត្រៀមយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអគ្គិសនីចំនួន២៤ច្បាប់

២-ការត្រៀមយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ជលផល

៣-ការត្រៀមបោះឆ្នោតជ្រើសរើសបំពេញសមាជិកនៃគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា។

**❈កិច្ចប្រជុំក្រុមសមាជរដ្ឋសភានិងព្រឹទ្ធសភា (ក្រុមទី៤) ចំនួន១លើក**

នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ**

ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំក្រុមសមាជរដ្ឋសភានិងព្រឹទ្ធសភា (ក្រុមទី៤) ដើម្បីពិភាក្សាលើ៖



១-ការត្រៀមរបស់ក្រុមសមាជរដ្ឋសភានិងព្រឹទ្ធសភា របស់សមាជិកព្រឹទ្ធសភាក្រុមទី៤ ដើម្បីចូលរួមផ្តល់យោបល់លើរបៀបវារៈទាំងបី នៃអង្គសមាជរដ្ឋសភានិងព្រឹទ្ធសភា នាថ្ងៃទី២ និងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៥

២-ផ្សេងៗ។

**❈កិច្ចប្រជុំក្រុមពហុភាគី ចំនួន១លើក**



នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃបណ្តាញប្រព្ធ័កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា តាមប្រព័ន្ធនិម្មិត (Visioconférence) ដើម្បីពិភាក្សាកម្មវិធី និងប្រធានបទសម្រាប់មហាសន្និបាតប្រចាំឆ្នាំ នៃបណ្តាញប្រព្ធ័កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក**

នាព្រឹកថ្ងៃសៅរ៍ ទី១៧ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ម៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំ



ផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងសម្រេចលើសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារប្រចាំខែមិថុនានិងលើកទិសដៅការងារបន្ត។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ចំនួន១លើក**



នារសៀលថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពនិងលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែឧសភា ព្រមទាំងទិសដៅការងារសម្រាប់ខែមិថុនា ឆ្នាំ២០២៥

២-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ចំនួន១លើក**

នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ដើម្បីពិនិត្យពិភាក្សាលើ៖

១-ផែនការយុទ្ធសាស្ត្រ៦ឆ្នាំ (២០២៤-២០៣០)

២-ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤

៣-បញ្ហាផ្សេងៗ។

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារ នៅតាមបណ្ដាភូមិភាគទាំង៨

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ កម្មករ ព្រមទាំងដឹកនាំក្រុមការងារចុះណែនាំអំពីរបៀបកាត់មែក និងថែទាំដើមឈើច្រើនប្រភេទ នៅជួរភ្នំម្រះព្រៅ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥។

-ដឹកនាំសិស្សានុសិស្សចូលរួមដាំកូនឈើផ្ចង់ជុំវិញមាត់ស្រះ នៅភូមិក្រាំងលាវ ឃុំរវៀង ស្រុកសំរោងទង ខេត្តតាកែវ នាព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ កម្មករ ព្រមទាំងពិនិត្យថ្នាលបណ្ដុះកូនឈើ ពិនិត្យចម្ការក្រូចថ្លុង និងណែនាំពួកគាត់អំពីរបៀបផ្សាំបណ្ដុះកូនឈើ ដើម្បីត្រៀមដាំនៅរដូវវស្សាខាងមុខ នៅភូមិព្រៃខ្យាំ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចុះពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និងផ្ដល់អនុសាសន៍ដល់ប្រជាពលរដ្ឋ អំពីរបៀបថែទាំដំណាំគ្រប់ប្រភេទ នៅភូមិមហាលំពាំងទី២ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចុះពិនិត្យវឌ្ឍនភាពនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីទុកជូនប្រជាពលរដ្ឋប្រើប្រាស់ នៅភូមិស្វាយជង្គំ និងជួបសំណេះសំណាលនិងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យចំការដូងក្រអូប និងបានណែនាំអំពីរបៀបថែទាំ ដើម្បីទទួលបានផលល្អប្រសើរ នៅភូមិព្រៃខ្យាំ ឃុំសែនជ័ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាកសិករ និងកម្មករ ព្រមទាំងចុះពិនិត្យដំណើរការសកម្មភាពកសិដ្ឋានបូកគោទី៣ និងទីតាំងបន្សុទ្ធពូជចំណីសត្វប្រកបដោយគុណភាព បច្ចេកទេស សុវត្ថិភាព អនាម័យ និងការចូលរួមចំណែកក្នុងការការពារបរិស្ថាន និងឧបត្ថម្ភថវិកាមួយចំនួនដល់ពួកគាត់ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៥។

-ដឹកនាំប្រជាពលរដ្ឋស្ម័គ្រចិត្តនិងកម្មករ ចូលរួមដាំដើមមៀនយូហ៊ុតចំនួន១.២២០ដើម នៅភូមិសំរោងជើងភ្នំ ព្រមទាំងជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ កម្មករ និងចុះដាំដើមក្រញូង ជុំវិញស្រះទឹកចំនួន១៨០ដើម នៅភូមិមហាលំពាំងទី២ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងកម្មករ ព្រមទាំងណែនាំអំពីរបៀបដាំដើមមៀន និងថែទាំដើម្បីឆាប់បានផល នៅភូមិដូនអាត់ ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ អញ្ជើញធ្វើដំណើរសម្រាកកម្សាន្ត ឆ្លងកាត់ខេត្តកំពង់ធំ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ពួកគាត់ នៅក្រុងស្ទឹងសែនខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សមកពីសាលារៀន (Guang Zhao) និងសាលា (SIS) មកបំពេញទស្សនកិច្ចសិក្សានិងជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋមកពីស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលមកសម្រាកកម្សាន្តនិងទស្សនា នៅក្នុងរមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងចុះពិនិត្យមើលក្រុមការងារគ្រឿងចក្រដែលកំពុងសម្រុកជួសជុលផ្លូវក្រាលគ្រួសក្រហម ដែលមានទទឹងប្រវែង១១ម៉ែត្រ និងបណ្ដោយប្រវែង១៤.០០០ម៉ែត្រ ព្រមទាំងជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាកសិករកំពុងធ្វើស្រែចម្ការ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ពួកគាត់ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខកម្មករកំពុងប្រមូលផលផ្លែមៀន នៅភូមិស្វាយជង្គំ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃអង្គារ ទី៦ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមបុណ្យគម្រប់៧ថ្ងៃ ភរិយាលោកអនុសេនីយ៍ត្រី **គឹម សារិ** កងទ័ពបម្រើការងារនៅកងពលលេខ៩ នៅខេត្តព្រះវិហារ ព្រមទាំងបាននាំយក



ថវិកាមួយចំនួនរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ និងថវិកាសមាគមនារីចូលបច្ច័យ នៅភូមិកន្សោមអក ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

❈នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តការងាររបស់ក្រុមការងារចុះមូលដ្ឋានខេត្តស្វាយរៀង ប្រចាំឆមាសទី១ និងទិសដៅភារកិច្ចសម្រាប់អនុវត្តប្រចាំឆមាសទី២ ឆ្នាំ២០២៥ ក្រោមអធិបតីភាពសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តស្វាយរៀង។



❈នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី «ការកំណត់លក្ខខណ្ឌនៃការប្រើប្រាស់ដីនិងការគ្រប់គ្រងនគរូបនីយកម្ម និងសំណង់ក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក» ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសណ្ឋាគារបាយ័នអេរ៉ា ខេត្តសៀមរាប។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលសួរសុខទុក្ខនិងពិភាក្សាការងារជាមួយសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥។

-ជួបពិភាក្សាការងារជាមួយសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ និងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់កែលម្អសាលប្រជុំ និងជូនដល់រដ្ឋបាលឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃអាទិត្យ ទី១១ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមខួបលើកទី១៦២ ទិវាកាកបាទក្រហមកម្ពុជា ក្រោមប្រធានបទ «រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ» ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅខេត្តតាកែវ។

❈ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ប្រគល់ប៊ិចមួយឈុតជូនដល់សាលាបឋមសិក្សាកន្ទួយវៃស្ថិតក្នុងសង្កាត់ចេក ក្រុងស្វាយរៀង ព្រមទាំងបាននាំយកសៀវភៅប្រវត្តិរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ចំនួន៣៥

ក្បាល ជូនសាកលវិទ្យាល័យស្វាយរៀង ក្នុងខេត្តស្វាយរៀង នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥។



-ចូលរួមដាំដើមក្រោកប៉ៃលិន ចំនួន៤០ដើម នៅជុំវិញបរិវេណសាលាឃុំចំបក់ ស្ថិតក្នុងឃុំចំបក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៥។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាអធិបតីក្នុងពិធីប្រគល់ឯកសណ្ឋាន ចំនួន៦៥កំប្លេ (ខោ អាវ មួក ខ្សែក្រវាត់) វិទ្យុទាក់ទងចំនួន៤៥គ្រឿង និងដំបងភ្លើងចរាចរណ៍ ចំនួន២០ដើម ជូនដល់ប្រជាការពារភូមិជាប់ព្រំដែនចំនួន៥ រួមមាន៖ ភូមិតេជោភ្នំធំត្រ ភូមិចំការគ ភូមិល្បើកស្វាយ ភូមិបឹងស្នោ និងភូមិចក់ពួក នៅសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥។

-នាំយកមី ចំនួន៧០កេស ជូនដល់រដ្ឋបាលសង្កាត់និមិត្ត



ដើម្បីត្រៀមទុកជូនដល់បងប្អូនប្រជាពលរដ្ឋជួបការលំបាកក្នុងស្ថានភាពណាមួយដែលកើតមានឡើងដោយថាហេតុ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលជាមួយក្រុមការងារប្រចាំការរបស់គណៈកម្មការ សម្រាប់ត្រៀមបង្ការជាយថាហេតុនូវសភាពការណ៍សន្តិសុខព្រំដែននិងសន្តិសុខ សណ្តាប់ធ្នាប់ផ្ទៃក្នុង និងបានឧបត្ថម្ភថវិកាមួយចំនួន នៅសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥។

❋នាថ្ងៃព្រហស្បតិ៍ ទី៨ ខែមុថុនា ឆ្នាំ២០២៥ លោកជំទាវ **ឃួន យុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពលោក **ជឹម សុខណ្ណា** ប្រធានសាខាពន្ធដារខេត្តកំពង់ធំ នៅភូមិពោធិ៍បាក់ក សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។

❋ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាល និងជូនដំណើរបងប្អូនសាសនិកអ៊ិស្លាមចំនួន៥០នាក់ និងជូនដំណើរជើមអះហាជ្ជីជើងទី៦ ចំនួន៩៧នាក់ ទៅបំពេញកាតព្វកិច្ចបុណ្យហាជ្ជីទៅធ្វើបុណ្យហាជ្ជីនៅទីក្រុងម៉ាកាស់ ប្រទេសអារ៉ាប៊ីសាអូឌីត នាថ្ងៃទី២៦



ខែមិថុនា ឆ្នាំ២០២៥។

-ចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសព ប្រជាពលរដ្ឋ នៅភូមិស្រែ (ត្រពាំងស្នាច់) សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងពិធីបុណ្យហាជី ស្ថិតក្នុងភូមិបឹងតារោង ឃុំព្រៃឃ្មុំ ព្រមទាំងចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៧ ថ្ងៃទី៨ និងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥។



❈នាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **កុល សៅរ៍ធន** សមាជិកាគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសំណេះសំណាលនិងចែកវិញ្ញាបនបត្រ ថ្នាក់ឧត្តមសិក្សានិងក្រោយឧត្តមសិក្សាដល់សិស្ស និស្សិត ចំនួន៤២៨នាក់ មកពីខេត្តកំពត ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅសាលសន្និសីទបូកគោ សាលាខេត្តកំពត។

❈នាថ្ងៃទី៣០ ខែឧសភា ២០២៥ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញនាំយកថវិកាផ្ទាល់ខ្លួន ដើម្បីស្ថាបនាផ្លូវក្រាលគ្រួសក្រហមមួយខ្សែ ប្រវែង២៦៨ម៉ែត្រ ទទឹង៥ម៉ែត្រ កម្រាស់គ្រួសក្រហម១២



សង់ទីម៉ែត្រ នៅភូមិស្នាកណ្ដាល ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

❈លោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាគណៈអធិបតីក្នុងពិធីសំណេះសំណាលជាមួយកុមារ ចំនួន៣០០នាក់ មកពីគ្រួសារដែលមានជីវភាពលំបាក ដើម្បី



អបអរខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ១មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៥ ព្រមទាំងបានយកអំណោយរបស់ឯកឧត្តម **ឃួង ស្រេង** អភិបាល និងលោកជំទាវ **គិមា ទិច្ចិភាល** អភិបាលរងរាជធានីភ្នំពេញ រួមមាន៖ សម្ភារៈសិក្សា ទឹកដោះគោស្រស់ ថវិកាមួយចំនួនដល់កុមារ និងបាននាំយកទេយ្យទាននិងបច្ច័យមួយចំនួនប្រគេនព្រះចៅអធិការវត្តឥន្ទពិសី នៅសង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥។



-ជាអធិបតីក្នុងពិធីជួបសំណេះសំណាល សួរសុខទុក្ខ

ប្រជាពលរដ្ឋ និងក្រុមសហជីព មកពីភូមិទាំង៥ ក្នុងសង្កាត់ផ្សារដើមថ្កូវ នៅខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥។

❈ឯកឧត្តម **អ៊ឹង លាងហ៊្វ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលរបស់សមាជិកក្រុមប្រឹក្សាឃុំ និងយុវជនស្រុកកំពង់លែង នៅសាលាស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥។



-ចូលរួមព្រះរាជពិធីចម្រើនព្រះជន្មគម្រប់៨៩ យាងចូល៩០ព្រះវស្សា សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា នៅវត្តចន្ទប្បជោត្តនារាម ភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខ និងធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ ព្រមទាំងឆ្លៀតឱកាសសំណេះសំណាលជាមួយក្រុមការងារចុះឈ្មោះបោះឆ្នោត នៅសង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-នាំយកទេយ្យទាននិងបច្ច័យមួយចំនួនវេរប្រគេនជូនព្រះសង្ឃនៅវត្តព្រះឥន្ទកោសីយ៍ វត្តព្រះឥន្ទកោសារ វត្តអង្គខាងជើង និងវត្តស្វាយធំ ក្នុងខេត្តសៀមរាប នាថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៥។

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី «ការកំណត់លក្ខខណ្ឌនៃការប្រើប្រាស់ដីនិងការគ្រប់គ្រងនគរូបនីយកម្ម និងសំណង់ក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារបាយ័នអេរ៉ា ខេត្តសៀមរាប នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥៕

## ការទទួលពាក្យបណ្តឹង

❈ក្នុងខែមិថុនា ឆ្នាំ២០២៥ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចូលចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន៩បណ្តឹង (ខែឧសភា ៣បណ្តឹង និងខែមិថុនា ៦បណ្តឹង) តម្កល់ទុកមិនចាត់ការចំនួន៣បណ្តឹង កំពុងពិនិត្យសិក្សាចំនួន២បណ្តឹង (ខែមេសា ១បណ្តឹង និងខែមិថុនា ១បណ្តឹង) ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន៣បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូនសម្តេចតេជោប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន១បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងចំនួន១២បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន៣បណ្តឹង៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នាល្ងាចថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១០រូប បានយាង/អញ្ជើញចូលរួមក្នុងកម្មវិធី Gala រៀបចំឡើងដើម្បីផ្ដល់អាហាររូបករណ៍ដល់យុវជនខ្មែរក្រីក្រសម្រាប់ការសិក្សារបស់ពួកគេ ចាប់ពីថ្នាក់បឋមសិក្សារហូតដល់បរិញ្ញាបត្រ នៅសណ្ឋាគារ Raffles Hotel Le Royal រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១៧រូប បានយាង/អញ្ជើញចូលរួមពិធីបូជាសពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** អតីតសមាជិកព្រឹទ្ធសភានិងជាទីប្រឹក្សាសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅឈាបនដ្ឋានមុខវត្តបទុមវតីរាជវរារាម។

❈នារសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១១រូប បានអញ្ជើញចូលរួមពិធីអបអរសាទរការដំណើរការជាផ្លូវការ ១ឆ្នាំ របស់សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិសាភោជនាហារសាមគ្គី ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍ កោះពេជ្រ។

❈នាព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **ឌី ច័ន្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីចម្រើនអាយុវឌ្ឍនៈមង្គល សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានកិត្តិយស នៃក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា គម្រប់៩១ ឈានចូល៩២ឆ្នាំ និងសម្ពោធឆ្លងសាលាបុណ្យ ព្រមទាំងប្រាសាទមរតកចក្រី នៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។



❈ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **សាយ ឫទ្ធិរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលជូនពរសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានកិត្តិយស នៃក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យចម្រើនជន្មាយុគម្រប់៩១ ឈានចូល៩២ឆ្នាំ នៅភូមិគ្រឹះសម្ដេច ក្នុងក្រុងតាខ្មៅ ខេត្តកណ្ដាល នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមការធ្វើដំណើរថ្មើរជើង «Solidarity March» ក្រោមការដឹកនាំរបស់ឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) ដើម្បីចូលរួមចំណែកក្នុងខឿនការពារជាតិប្រជាជន តាមរយៈការបង្ហាញពីឆន្ទៈមនសិការ ស្នេហាជាតិ ទឹកដី និងបង្ហាញការរួមគ្នាជាធ្លុងមួយ គាំទ្រដល់រាជរដ្ឋាភិបាលនិងកងកម្លាំងការពារជួរមុខ នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា



លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ ព្រឹទ្ធសភា និងលោកជំទាវ **ចឹក ហេង** សមាជិកាគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកព្រឹន្ទបាលឯក **សួន រ៉ោន** ដែលទទួលមរណភាព ក្នុងហេតុការណ៍ប៉ះទង្គិចរវាងកងទ័ពកម្ពុជា និងកងទ័ពថៃ នៅតំបន់ព្រំដែនមុំបី កាលពីព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ព្រមទាំងបាននាំយកបន្លែ ត្រី សាច់ គ្រឿងទេស អង្ករ គេសជ្ជៈ ថវិកាប្រគល់ជូនដល់ទីបញ្ជាការកងពលលេខ៩ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។



❈នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ ព្រឹទ្ធសភា និងលោកជំទាវ **ចឹក ហេង** សមាជិកាគណៈកម្មការព្រឹទ្ធសភា តំណាងឯកឧត្តមបណ្ឌិត **នាង ផាត** ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកព្រឹន្ទបាលឯក **សួន រ៉ោន** ដែលទទួលមរណភាពក្នុងហេតុការណ៍ប៉ះទង្គិចរវាងកងទ័ពកម្ពុជា និងកងទ័ពថៃ នៅតំបន់ព្រំដែនមុំបី ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីសម្ពោធផ្សារទំនើបជីបម៉ុង តាខ្មៅ នៅផ្សារតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល នាព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥។

-ចូលរួមពិធីអបអរសាទរប្រវត្តិសាស្ត្រ និងតន្ត្រីហ្វីលីពីន ក្នុងឱកាសខួបលើកទី១២៧ នៃសាធារណរដ្ឋហ្វីលីពីន នៅ Angkor grand Phnom Penh នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០២៥។

❈ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីពិសាអាហារពេលល្ងាច ជាមួយលោក Bernard Philip ជំនួយការលេខាទីមួយផ្នែកគោលនយោបាយអន្តរជាតិ អូស្ត្រាលី នៅភោជនីយដ្ឋាន Malis រាជធានីភ្នំពេញ នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៥។

-ចូលរួមក្នុងពិធីជួបជុំអតីតនិស្សិតឃោជាកម្ពុជា-អូស្ត្រាលី ឆ្នាំ២០២៥ នៅសណ្ឋាគារ Raffles Hotel Le Royal រាជធានីភ្នំពេញ នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥។

❈ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖

-ផ្ដល់បាឋកថាស្ដីពី «គោលនយោបាយការបរទេសនិង



វិស័យការទូតសភា» តបតាមសេចក្តីអញ្ជើញរបស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ហោ ម៉េង** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។

-ចូលរួមកម្មវិធីសំណេះសំណាលជាមួយគណៈប្រតិភូពាណិជ្ជកម្មកាណាដា ដឹកនាំដោយកញ្ញា Sara Wilshaw ប្រធានពាណិជ្ជកម្មកាណាដាជាមួយនឹងក្រុមហ៊ុន៨០ទៀត នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅរាជធានីភ្នំពេញ នាថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុធ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **ង៉ាន់ ចំរើន** អនុប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមឆ្ពោះទៅការរៀបចំកិច្ចប្រជុំក្រុមអ្នកនយោបាយអាយប៉ា (AIPA



Caucus) លើកទី១៦ និងចូលរួមកម្មវិធី AIPA Roadshow ក្រោមអធិបតីភាពឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥រដ្ឋសភា នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។



❈នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសកែសម្រួលនិងបំពេញបន្ថែមសមាសភាពគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកណ្តាល។




❈នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** អតីតសមាជិកព្រឹទ្ធសភា និងជាទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខនិងនាំយកថវិការបស់ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ឆន់ ខឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា ប្រគល់ជូនលោកស្រី **ភាន ឡឹង** ភរិយា និងកូនទាំង៦នាក់ របស់សពលោកព្រិន្ទបាលឯក **ឡឿន គីន** ទាហានជួរមុខវរៈសេនាតូចលេខ៤០៣ ឈរជើងនៅតំបន់ជាំស្រងាំ និងប្រាសាទតាមាន់ ដែលមកស្នាក់នៅបណ្តោះអាសន្នជាមួយម្តាយ នៅភូមិកប់ថ្លុក ឃុំជំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

❈នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ (Global Life sharing) រួមមាន៖ ឱសថ បរិក្ខារពេទ្យ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ប្រគល់ជូនរដ្ឋបាលខេត្តកំពង់ស្ពឺ ដឹកនាំដោយឯកឧត្តមបណ្ឌិត **វ៉ាង ច័ន្ទសោភ័ណ** អភិបាល នៃគណៈអភិបាលខេត្ត នៅសាលាខេត្តកំពង់ស្ពឺ។



❈នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម

បណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** អតីតសមាជិកព្រឹទ្ធសភា និងជាទីប្រឹក្សាសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ខ៉ែត ចន្ថាវី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យសពឯកឧត្តម **អ៊ុំ ញ៉ាញ់** អតីតសមាជិករដ្ឋសភាមណ្ឌលភ្នំពេញ សម្រាប់នីតិកាលទី២ ទី៣ និងទី៤ និងជាទីប្រឹក្សាជាន់ខ្ពស់រដ្ឋសភាជាតិដែលបានទទួលមរណភាពក្នុងជន្មាយុ៨៦ឆ្នាំ ដោយរោគាពាធ នៅរាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **ចឹក ហេង** សមាជិកាគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារសិក្សា អគារទីចាត់ការ អគារសយនដ្ឋាន អគារពិសោធន៍ និងសមិទ្ធផលនានានៅក្នុងខេត្តរតនគិរី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។



❈នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់មេដាយ និងវិញ្ញាបនបត្រជូនដល់សិស្សដែលទទួលបានជ័យលាភីក្នុងការប្រកួតជំនាញគិតនិងវិភាគដោយប្រើគណិតកុំព្យូទ័រ នៅរាជធានីភ្នំពេញ។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំគណៈកម្មការ និងអនុគណៈកម្មការរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរនិងសុភមង្គល ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្ដាលកាកបាទ



ក្រហមកម្ពុជា នារសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥។



-អមដំណើរលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា អញ្ជើញចូលក្រាបថ្វាយបង្គំគាល់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីថ្វាយព្រះរាជសព្ទសាធុការពរជ័យ និងទូលថ្វាយរបាយការណ៍ នៅព្រះមហាប្រាសាទខេមរិន្ទ ព្រះបរមរាជវាំង នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥។



-នាំយកទេយ្យវត្ថុ ទេយ្យទានមួយចំនួនធំ ជាសទ្ធាជ្រះថ្លារបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រគេនជូនវត្តកែវសិក្ខាគិរីស្វារៈ មានដូចជា៖ អង្ករ ចំនួន១តោន, មីចំនួន២០កេស, ត្រីខចំនួន៥កេស, ត្រីងៀតចំនួន១កន្ត្រក សាច់ក្រក ចំនួន២កន្ត្រក, ផ្លែប៉ោមចំនួន១កេស, ផ្លែទំពាំង-បាយជូចំនួន១កេស, ផ្លែក្រូចឃ្វិចចំនួន២កេស, ទឹកបរិសុទ្ធចំនួន២០កេស, ទឹកក្រូចចំនួន១០កេស, ទឹកផ្លែឈើចំនួន១០កេស, មៀនកំប៉ុង ចំនួន៥កេស, ទឹកដោះគោខាប់ចំនួន២កេស, អូវ៉ាន់ទីនចំនួន២កេស, ស្ករ-សចំនួន១បាវ, តែក្លោកចំនួន១ដុំ (ស្មើនឹង៥០០ក្រាម), ទឹកស៊ីអ៊ីវចំនួន២០យួររថយន្តភីកអាប់ Ford Ranger ចំនួន១គ្រឿងនិងបច្ច័យមួយចំនួន ប្រគេនព្រះចៅអធិការវត្ត នូវសាដកចំនួន១ និងបច្ច័យមួយចំនួន ប្រគេនព្រះសង្ឃ៥អង្គ ក្នុង១អង្គៗ សាដកចំនួន១ និងបច្ច័យមួយចំនួន ព្រមទាំងបានជូនឃីត (សារុង ក្រមា មុងភួយ) និងថវិកាមួយចំនួនដល់លោកតាអាចារ្យនិងលោកតាលោកយាយ រួមទាំងពុទ្ធបរិស័ទជាច្រើនទៀត នាថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៥។

❈សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង៖

-ជាកិត្តិយសក្នុងឱកាសសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះរាជានុញ្ញាតជូនឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីអញ្ជើញចូលក្រាបថ្វាយបង្គំគាល់ ស្ថិតនៅព្រះបរមរាជវាំង នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥។



-ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពង់បំផុត ក្នុងពីធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ-សម្តេចម៉ែ នៅខេត្តស្ទឹងត្រែង នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥។

-នាំយកនូវព្រះរាជអំណោយរបស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពង់បំផុត

ប្រទាននូវព្រះរាជទ្រព្យមួយចំនួន និងព្រះរាជអំណោយទ្រង់ផ្ទាល់មួយចំនួន ជូនដល់វិទ្យាល័យបារាំងអន្តរជាតិ **នរោត្តម មុនិនាថ សីហនុ** នាល្ងាចថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥។



-ជាកិត្តិយសក្នុងពិធីអបអរសាទរព្រឹទ្ធាចារ្យរាជបណ្ឌិតសភាចារ្យ **ប៉ែន សុខហួន** នាឱកាសទទួលបានមេដាយថ្នាក់អស្សប្រទិ្ធ ផ្នែកដឹកនាំ និងតម្លើងរបាំព្រះរាជទ្រព្យពីសាធារណរដ្ឋបារាំង តាមរយៈស្ថានទូតបារាំងប្រចាំកម្ពុជា នៅស្ថានទូតបារាំង រាជធានីភ្នំពេញ នាល្ងាចទី១១ ខែមិថុនា ឆ្នាំ២០២៥។

-ជាកិត្តិយសក្នុងឱកាសសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះរាជានុញ្ញាតជូនឯកឧត្តម **ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា អញ្ជើញចូលក្រាបថ្វាយបង្គំគាល់ នៅព្រះបរមរាជវាំង នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖




-ចូលរួមកិច្ចប្រជុំរួមគ្នារវាងថ្នាក់ដឹកនាំអាយប៉ា និងប្រមុខដឹកនាំអាស៊ាន ដើម្បីពិភាក្សាលើសេចក្តីព្រាងសាររបស់អាយប៉ា ដែលឆ្លុះបញ្ចាំងលើប្រធានបទ «បរិយាបន្នភាព និងនិរន្តរភាព» នៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៦ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត Johari bin Abdul ប្រធានរដ្ឋសភាម៉ាឡេស៊ី និងជាប្រធានមហាសន្និបាតអាយប៉ា លើកទី៤៦ នៅវិមានរដ្ឋសភា នៃសហព័ន្ធម៉ាឡេស៊ី នៅប្រទេសម៉ាឡេស៊ី នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥។

-ចូលរួមពិធីបើកមហាសន្និបាតលើកទី១១ នៃតំបន់អាស៊ីប៉ាស៊ីហ្វិក ក្រោមអធិបតីភាពឯកឧត្តម Vaimu’a MULIAVA ប្រតិភូតំបន់ និងជាសមាជិកសភានូវ៉ែលកាឡេដូនី នៅ




សាលប្រជុំពេញអង្គនៃសភានូវ៉ែលកាឡេដូនី នៅប្រទេសបារាំង ពីថ្ងៃទី៧ ដល់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៥។

❈ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានយាងចូលរួមមហាសន្និបាតគណៈមេធាវីនៃសាធារណរដ្ឋបារាំង និងធ្វើបទបង្ហាញសង្ខេបស្តីពី ច្បាប់សាធារណរដ្ឋបារាំង និងក្រមរដ្ឋប្បវេណីរបស់កម្ពុជា នៅប្រទេសបារាំង៕

# ឯកឧត្តម ឡាយ សំកុល ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២៥



*ឯកឧត្តម ឡេក ឆាយ* *ឯកឧត្តម ឡាយ សំកុល* *ឯកឧត្តម អោក ប៉ូវ៉ា*

នាព្រឹកថ្ងៃសុក្រ ទី១៣ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង។

ក្នុងនាមមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា**បានចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពចំពោះមរណភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សា**សម្តេចតេជោប្រធានព្រឹទ្ធសភា** និងជាអតីតសមាជិកព្រឹទ្ធសភា និងក្រុមគ្រួសារសពលោក **មុន្នី មករា** មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា**បានរំលេចអំពីលទ្ធផលដ៏ត្រចះត្រចង់និងជោគជ័យ នៃដំណើរទស្សនកិច្ចរបស់**សម្តេចតេជោប្រធានព្រឹទ្ធសភា** ទៅកាន់ប្រទេសឥណ្ឌូណេស៊ី និងប្រទេសទីម័រឡេស្ត ព្រមទាំងការរៀបចំសមាជរដ្ឋសភានិងព្រឹទ្ធសភា កាលពីពេលកន្លងទៅថ្មីៗ។ ក្នុងនោះ សមាជរដ្ឋសភានិងព្រឹទ្ធសភា បានចេញសេចក្តីថ្លែងការណ៍គាំទ្រចំពោះយន្តការដោះស្រាយបញ្ហាព្រំដែនរបស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយប្រទេសថៃ តាមរយៈការទូត ការចរចា ស្វ័យការពារខ្លួន និងប្រើប្រាស់ច្បាប់អន្តរជាតិ។

**ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា**ក៏បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក នៃខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាទាំងបី និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានចូលរួមថវិកាឧបត្ថម្ភដល់កងកម្លាំងការពារព្រំដែន នៅខេត្តព្រះវិហារ។ ហើយកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ គណៈប្រតិភូព្រឹទ្ធសភាដឹកនាំដោយ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ឆន់ ទន្សា្ននា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខនិងនាំយកអំណោយជូនដល់កងកម្លាំងការពារព្រំដែន នៅកងពលតូចអន្តរាគមន៍លេខ៨និងកងកម្លាំងការពារព្រំដែនតំបន់មុំបី ខេត្តព្រះវិហារ និងអញ្ជើញគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី **សោ ឫទ្ធី** មេបញ្ជាការកងអនុសេនាតូចស៊ើបការណ៍ វរសេនាតូចលេខ៣៩២។

**ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា**បានណែនាំដល់គ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ត្រៀមចូលរួមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងការបន្តសម័យប្រជុំលើកទី៣ ព្រឹទ្ធសភានីតិកាលទី៥ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២៥ច្បាប់។ ចំពោះការងារអភិវឌ្ឍស្ថាប័ន **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា**បានស្នើសុំឱ្យ



ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុប

**ឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា នាយករងខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា** និង**ឯកឧត្តមអគ្គនាយក-ព័ត៌មាន និងទំនាក់ទំនងសាធារណៈ** រៀបចំកសាងឯកសារទស្សនទានស្តីពី ការរៀបចំសិក្ខាសាលាស្តីពី ការលើកកម្ពស់ការយល់ដឹងអំពីបញ្ញាសិប្បនិម្មិត(AI) និងអភិបាលកិច្ចឌីជីថល ដែល**ឯកឧត្តមប្រធានគណៈកម្មការទី១ព្រឹទ្ធសភា**បានស្នើឡើង។ ទន្ទឹមគ្នានោះ **ឯកឧត្តមអគ្គលេខាធិការ**បានផ្តួចផ្តើមគំនិតក្នុងការរៀបចំសៀវភៅស្តីពី ប្រវត្តិអគារនានាក្នុងបរិវេណវិមានព្រឹទ្ធសភា និងខិតខំធ្វើយ៉ាងណាឱ្យរួចរាល់ស្របពេលដែលអគារវិមានព្រឹទ្ធសភាថ្មីត្រូវបានសាងសង់រួច និងសម្ពោធឱ្យប្រើប្រាស់នាពេលខាងមុខ។ ឯកឧត្តមបានជម្រាបអំពីវឌ្ឍនភាពនៃជំនួយរបស់ប្រទេសចិនលើគម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលបន្ទុកទិន្នន័យ និងការត្រៀមបែងចែកកុំព្យូទ័រដែលជាជំនួយរបស់ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ ដែលនឹងមកដល់នាពេលខាងមុខ។ ទន្ទឹមគ្នានោះ ឯកឧត្តមបានណែនាំឱ្យរៀបចំតម្រូវការអភិវឌ្ឍន៍ធនធានមនុស្សតាមវិស័យ និងជំនាញនៅក្នុងអង្គភាពរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមុននឹងសម្រេចសម្រួលជាមួយសាកលវិទ្យាល័យនានា ដើម្បីស្នើសុំអាហារូបករណ៍សម្រាប់មន្ត្រី នៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា។

**ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា**បានណែនាំដល់អង្គភាពបេឡាសោធននិវត្តន៍ គិតគូររៀបចំឯកសារពាក់ព័ន្ធនឹងចំនួនមន្ត្រីចូលនិវត្តន៍ និងការចំណាយថវិកាលើការចូលនិវត្តន៍របស់មន្ត្រី តាមឆ្នាំនីមួយៗ ដោយធ្វើការវាយតម្លៃអំពីស្ថានភាព និងនិរន្តរភាពរបស់បេឡាក្នុងរយៈពេលវែងពី៥ទៅ២០ឆ្នាំខាងមុខ។ ជាមួយគ្នានោះ ឯកឧត្តមបានណែនាំដល់នាយកដ្ឋានព័ត៌មាន ឱ្យពិនិត្យ និងសម្រួលខ្លឹមសារអត្ថបទព័ត៌មានដែលបានដកស្រង់ពីប្រភពនានាឱ្យបានល្អប្រសើរ មុននឹងចុះផ្សាយក្នុងទស្សនាវដ្តីព្រឹទ្ធសភាប្រចាំខែនីមួយៗ។

មុននឹងបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា**បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់អង្គភាពទាំងអស់ ដែលបានខិតខំបំពេញការងារបានល្អប្រសើរនិងស្នើឱ្យបន្តខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ស្ថាប័ននិងប្រទេសជាតិ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២៥

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នាយប់ថ្ងៃអង្គារ ទី៣ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា និងជាអគ្គលេខាធិការសមាជរដ្ឋសភានិងព្រឹទ្ធសភា បានអញ្ជើញធ្វើសន្និសីទសារព័ត៌មានស្តីពី លទ្ធផលនៃកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា នៅវិមានរដ្ឋសភា។



❈នារសៀលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញនាំយកជង្វាយរបស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ថ្វាយសម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសចម្រើនព្រះជន្មាយុគម្រប់ ៨៩ព្រះវស្សាយាងចូល៩០ព្រះវស្សា នៅព្រះបរមរាជវាំង។



❈នាព្រឹកថ្ងៃសៅរ៍ ទី១៤ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ លោក **មុន្នី មករា** មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅភូមិកំពង់ ឃុំព្រះបាទ-ជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ។



❈នាព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមការងារបច្ចេកទេសសាងសង់អគារ បានអញ្ជើញចូលរួមកិច្ចប្រជុំ និងចុះពិនិត្យមើលវឌ្ឍនភាពដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា ក្រោមអធិបតីភាពឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ពាំនាំនូវការសួរសុខទុក្ខនិងនាំយកអំណោយឧបត្ថម្ភនានារបស់**សម្តេចតេជោ** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** មានដូចជាគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់មួយចំនួន ជូនបងប្អូនកងទ័ពជួរមុខ នៅកងពលធំអន្តរាគមន៍លេខ២ ខេត្តឧត្តរ-មានជ័យ។



❈នៅថ្ងៃពុធ ទី២៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសម្តែងការគួរសមចំពោះឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត **ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងអង្គរក្ស និងបានបន្តសំណេះសំណាលជាមួយកងកម្លាំងឈរជើងនៅប្រាសាទតាមាន់ ខេត្តឧត្តរ-មានជ័យ។



❈នាព្រឹកថ្ងៃចន្ទ ទី៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ខេង សិទ្ធិកុណា** បានអញ្ជើញនាំយកថវិការបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ចូលបុណ្យសពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សា**សម្តេចតេជោប្រធានព្រឹទ្ធសភា** និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅរាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃសុក្រ ទី៦ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលប្រជុំពិសេសជាន់ក្រោមវិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



❈នៅរសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ឯកឧត្តម **អោក ប៊ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធលោកព្រឹន្ទបាលឯក **សួន រ៉ោន** ដែលបានពលីនៅក្នុងហេតុការណ៍ផ្ទុះអាវុធរវាងកងទ័ពថៃនិងកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ នៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។



❈នាព្រឹកថ្ងៃអង្គារ ទី៣ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ជាម សុផលមករា** អគ្គនាយកព័ត៌មាន និងទំនាក់ទំនងសាធារណៈ បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារសំខាន់ៗរបស់ អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ និងបញ្ហាផ្សេងៗ នៅបន្ទប់ប្រជុំនាយកដ្ឋានព័ត៌មានវិទ្យា។



❈នាព្រឹកថ្ងៃសុក្រ ទី១៣ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ខួន សុខវេង** អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ បានអនុញ្ញាតជូនកម្មសិក្សាការី កញ្ញា Charlotte TONELLI ជានិស្សិតឆ្នាំទី៣ Sciences Po Aix-en-Provence ផ្នែកទំនាក់ទំនងអន្តរជាតិប្រទេសបារាំង ចូលជួបសម្តែងការគួរសម និងជម្រាបលា នៅអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ។



❈ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំធ្វើបច្ចុប្បន្នភាពបណ្ណសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ជូនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងមន្ត្រីរាជការជានិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា៕

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
ទូរស័ព្ទ: (855) 23 211 441, 211 442, 211 443 ទូរសារ: (855) 23 211 446
E-mail: secretariat@senate.gov.kh
www.senate.gov.kh www.elibrary.senate.gov.kh
senate of cambodia